## ៣. ការអធិប្បាយអំពីគំរោង

### ៣-១ សាវតាក្រុមហ៊ុន

**២៤.** ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ (TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD)** ជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត បានចុះបញ្ជីការនៅក្រសួងពាណិជ្ជកម្ម ជាមួយនឹងទុនចុះបញ្ជីការដំបូងចំនួន ២០លានរៀល។ ក្រុមហ៊ុនគ្រោងវិនិយោគនូវទឹកបាក់ចំនួន **៤៩.៤២៤.០៦២.00** ដុល្លាអាមេរិក ដើម្បីចំណាយលើការដាំដុះដំបូង-ការសាងសង់សំណង់ស៊ីវិល ចំណាយលើការទិញមធ្យោបាយផលិតកម្ម និងចំណាយប្រតិបត្តិការអាជីវកម្មក្នុងដំណាក់កាល១០ឆ្នាំដំបូង នៃការវិនិយោគអភិវឌ្ឍន៏ដាំដុះកៅស៊ូ លើទំហំផ្ទៃដីចំនួន **៨.១០០ ហិកតា**។ ក្រុមហ៊ុនមានទីស្នាក់ការរបស់ខ្លួនស្ថិតនៅ ផ្លូវជាតិលេខ ៦ ភូមិដីជាន់ខ្លា ស្រុកស្ទឹងសែន ខេត្តកំពង់ធំ នៃព្រះរាជាណាចក្រកម្ពុជា។ ទូរស័ព្ទទំនាក់ទំនងលេខ (៨៥៥) ២៣ ៣៩៥ ៤២២ និងទូសារលេខ (៨៥៥)២៣ ២២២ ៩៧៥។

**២៥.** ភាគហ៊ុន និងសមាជិកភាគហ៊ុន : ក្រុមហ៊ុននេះ ជាក្រុមហ៊ុនទទួលខុសត្រូវមានកំរិត មានដើមទុនចុះបញ្ជីដែលបង្កើតឡើងដោយការដាក់បញ្ចូលភាគហ៊ុនពីសមាជិកនៃក្រុមហ៊ុន ដែលតំណាងដោយលោក **DUONG QUOC VIET** ជនជាតិវៀតណាម ឋានៈជាប្រធានក្រុមប្រឹក្សាភិបាល មានគណនីលេខ ០១០០-២៥០-០១៣-៨៧៧ នៅធនាគារវឌ្ឍនៈ។

### ៣-២ ទីតាំងភូមិសាស្ត្រ និងព្រំប្រទល់ដីសម្បទាន

**២៦.** ក្រុមហ៊ុន **TAN BIEN KAMPONG THOM APHIVATH CAOUT CHOUC CO., LTD.)** បានទទួលការប្រទាន សិទ្ធិពីរាជរដ្ឋាភិបាលក្នុង ការអភិវឌ្ឍន៏ដាំដំណាំកៅស៊ូ ដែលគ្របដណ្តប់លើផ្ទៃដីចំនួន **៨.១០០ហិកតា** មានភូមិសាស្ត្រ ស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ដែលមានចំណុចនិយាមកាដូចបង្ហាញ ជូនតារាងខាងក្រោម :

| ចំណុចគោលព្រំដីសម្បទាន | ចំណុចអាប់ស៊ីស (X) | ចំណុចអរដោនេ (Y) |
|---|---|---|
| A | ៥៤១៩៩០ | ១៣៨១៨៩២ |
| B | ៥៤១៩៩០ | ១៣៨៧៥១៤ |
| C | ៥៤៣៦១១ | ១៣៨៧៥១៤ |
| D | ៥៤៣៦១១ | ១៣៨៧៩៩៧ |
| E | ៥៤៧៩៩១ | ១៣៨៧៩៩៧ |
| F | ៥៤៧៩៩១ | ១៣៩១៦៨៧ |



Draft

| | | |
|---|---|---|
| G | ៥៤៩០៩៥ | ១៣៩១៩៩៨ |
| H | ៥៥២១២៤ | ១៣៩១៩៩៩ |
| I | ៥៥២១២៤ | ១៣៨៥៩០០ |
| J | ៥៥៧០៩៨ | ១៣៨៥៩០០ |
| K | ៥៥៧១៣១ | ១៣៧៧៩៩៥ |
| L | ៥៥៤៨៨៩ | ១៣៧៦៥១២ |
| M | ៥៦៩៩៩១ | ១៣៧៩៩៩៦ |
| N | ៥៤៩៩៩១ | ១៣៨១៩៩៦ |
| O | ៥៤៥៩៩១ | ១៣៨១៩៩៦ |

## ៣-៣ ស្ថានភាពលិខិតបទដ្ឋានច្បាប់នៃតមបន់សម្បទាន

**២៧.** ឯកសារគោលការណ៍ច្បាប់ដែលក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ (TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.)** ។ បានទទួលពីរាជរដ្ឋាភិបាលកម្ពុជា មានដូចខាងក្រោមៈ

- ❖ លិខិតលេខ ១៨៨៤ កសក. ចុះថ្ងៃទី ០៦ ខែ មេសា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីករណីសំណើសុំសម្បទានដីចំនួន ១០.០០០ ហិកតា របស់ក្រុមហ៊ុន **TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.** សម្រាប់វិនិយោគលើវិស័យកសិក-ឧស្សាហកម្ម ដាំកៅស៊ូ និងបង្កើតរោងចក្រកែច្នៃ ស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ សំរាប់វិនិយោគដំណាំកៅស៊ូ ។
- ❖ លិខិតជូនដំណឹងលេខ ៥០១ សជណ ចុះថ្ងៃទី ១១ ខែ មេសា ឆ្នាំ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីករណីសំណើសុំដីសម្បទានចំនួន ១០.០០០ ហិកតា របស់ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ (TAN BIEN KAMPONG THOM APHIVATH CAOUTCHO-UC CO., LTD.)** សម្រាប់វិនិយោគលើវិស័យកសិក-ឧស្សាហកម្ម ដាំកៅស៊ូ និងបង្កើតរោងចក្រកែច្នៃ ស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ ។
- ❖ លិខិតលេខ ២១០៧ កសក ចុះថ្ងៃទី ២៣ ខែ មេសា ឆ្នាំ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ស្តីពីសំណើសុំសិទ្ធប្រទានពីរាជរដ្ឋាភិបាល ដើម្បីចុះហត្ថលេខាលើកិច្ចសន្យាដីសម្បទានចំនួន ៨.១០០ ហិកតា សម្រាប់វិនិយោគលើវិស័យកសិក-ឧស្សាកម្ម ដាំកៅស៊ូ និងបង្កើតរោងចក្រកែច្នៃ ស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ របស់ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍**

Draft

**កៅស៊ូ (TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.)** ។

- សិទ្ធិប្រទានលេខ ៣៨ សប្រទ ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ប្រទានសិទ្ធិជូនឯកឧត្តមបណ្ឌិត **ចន្ទ័  សារុន** រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីចុះហត្ថលេខា លើកិច្ចសន្យាដីសម្បទានចំនួន ៨.១០០ ហិកតា ស្ថិតនៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ សម្រាប់វិនិយោគលើវិស័យ កសិ-ឧស្សាហកម្ម ដាំកៅស៊ូ និងបង្កើតរោងចក្រ កែច្នៃ ជាមួយក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ ( TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.)** ។
- កិច្ចសន្យាចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការវិនិយោគដាំដំណាំ កសិ-ឧស្សាហកម្ម ដាំកៅស៊ូ និងបង្កើតរោងចក្រកែច្នៃ រវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ (TAN BIEN KAMPONG THOM APHIVATH CAOUT CHOUC CO., LTD.)** (ភ្ជាប់ជូន ក្នុងឧបសម្ព័ន្ធ ៣-១) ។

## ៣-៤ ប្រវត្តិរបស់ដីសម្បទាន

**២៨.** ដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ដំណាំកសិ-ឧស្សាហកម្ម ក្រុមហ៊ុនបានពិនិត្យលទ្ធភាពវិនិយោគ និងបានស្នើសុំដីសម្បទានលើផ្ទៃដីប្រមាណ ៨.១០០ ហិកតា ពីរាជរដ្ឋាភិបាលកម្ពុជា សម្រាប់វិនិយោគលើវិស័យកសិ-ឧស្សាហកម្ម ដាំកៅស៊ូ និងបង្កើតរោងចក្រកែច្នៃ នៅក្នុងឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ។ យោងសំណើរបស់ក្រុមហ៊ុន ក្រុមអ្នកជំនាញបច្ចេកទេស របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចុះពិនិត្យជាក់ស្តែងនៅតំបន់ដីដែលស្នើសុំ ដោយបានសហការយ៉ាងជិតស្និទ្ធ ជាមួយអាជ្ញាធរដែនដី និងមន្ត្រីជំនាញមូលដ្ឋាន បានពិនិត្យឃើញថា ផ្ទៃដីចំនួន១០.០០០ហិកតានោះ មានផ្ទៃដីតែចំនួនត្រឹម ៨.១០០ហិកតា ប៉ុណ្ណោះ ដែលអាចផ្តល់ជូនក្រុមហ៊ុន ដើម្បីធ្វើការវិនិយោគបាន និងពិនិត្យឃើញថាស្ថានភាពព្រៃនៅតំបន់នោះ ត្រូវទទួលរងការធ្វើអាជីវកម្មអនាធិបតេយ្យដែលធ្វើឱ្យតំបន់ព្រៃនេះ ក្លាយជាព្រៃគ្មានគុណភាពសេដ្ឋកិច្ច។

**២៩.** លើផ្ទៃដីទំហំ ៨.១០០ ហិកតា ដែលរាជរដ្ឋាភិបាលបានផ្តល់ជូនក្រុមហ៊ុន ដើម្បីធ្វើវិនិយោគនេះត្រូវបានកាត់ចេញរួចហើយនូវផ្ទៃដីពាក់ពន្ធ័ដូចខាងក្រោម:

- ដីការស្តីពីការដកហូតមកវិញដើម្បីទុកជាសម្បត្តិរដ្ឋ នូវផ្ទៃដីដែលបានកាន់កាប់ដោយខុសច្បាប់ ទំហំ ៨៤០ ហិកតា (តែបើគណនាដោយកុំព្យូទ័រឃើញមានទំហំ ៩៦០ហិកតា) នៅក្នុងភូមិសាស្ត្រ ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ (ដីការលេខ ០៨២ ដរ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៦ របស់សាលាខេត្តកំពង់ធំ) ។

- ដីត្រៀមបំរុងទុកបង្កើតសហគមន៍ព្រៃឈើភូមិថ្មសំលៀង ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ មានទំហំ ៩៣១ ហិកតា។

- ដែនព្រៃបំរុងទុកសម្រាប់ស្តារឡើងវិញ និងសិក្សាស្រាវជ្រាវ ហើយទីតាំងនេះស្ថិតនៅលើដីស្នើសុំរបស់ ក្រុមហ៊ុនមានទំហំ ១.១៥០ ហិកតា។

- ព្រៃតំបន់ទ្រនាប់សំរាប់ការពារការហូរច្រោះសង់ខាងអូរម្ខាង ៥០០ ម៉ែត្រ មានទំហំ ៣.០១៧ ហិកតា។

ហេតុដូចនោះហើយទើបបានជាផ្ទៃដីបានថយមកនៅត្រឹមតែ ៨.១០០ ហិកតា សំរាប់ក្រុមហ៊ុនធ្វើអាជីវកម្ម។ តាមរយៈលទ្ធផលនៃការសិក្សានេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក៏បានឯកភាពលើមតិជំនាញ និងគោលការណ៍អនុញ្ញាតផ្តល់ដីសម្បទានសេដ្ឋកិច្ច ចំនួន ៨.១០០ហិកតា នេះជូនក្រុមហ៊ុន។

## ៣-៥ ការរៀបចំ និងគ្រប់គ្រងដីតំបន់វិនិយោគ

### ៣-៥-១ គោលបំណងនៃការធ្វើវិនិយោគ

៣០. គោលដៅចំបងលើការវិនិយោគលើដីតំបន់វិនិយោគនេះ គឺសំដៅចូលរួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចកសិកម្មប្រកបដោយនិរន្តរភាព និងជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជា តាមរយៈការវិនិយោគស្តារ និងបង្កើនផលិតកម្មកសិកម្ម ដោយការអភិវឌ្ឍន៍ចំការកៅស៊ូ និងការលើកកំពស់ប្រសិទ្ធភាពសេដ្ឋកិច្ចនៃព្រៃរេចរឹល កែលំអលំនឹងបរិស្ថានធម្មជាតិ ដោយបង្កើតឡើងចំការកៅស៊ូ និងការសាងសង់រោងចក្រកែច្នៃផលិតផលកៅស៊ូ។ បណ្តាប្រទេសមួយចំនួននៅសហគមន៍អាស៊ានដូចជា ម៉ាឡេស៊ី ឥណ្ឌូណេស៊ី វៀតណាម បានបង្វែរយុទ្ធសាស្ត្រពីការដាំដូងប្រេងមកធ្វើការដាំដំណាំកៅស៊ូវិញ ដោយមូលហេតុមានតំរូវការលើផលិតផលកៅស៊ូក្នុងទីផ្សារអន្តរជាតិ។ ម្យ៉ាងវិញទៀត ដំណាំកៅស៊ូក៏មានតួនាទីយ៉ាងសំខាន់ក្នុងការជំនួសជាតម្របព្រៃឈើដែលអាចបង្កើតឱ្យមាន បរិស្ថានល្អផងដែរ។ គោលបំណងលំអិតនៃតំបន់វិនិយោគនេះ មានដូចខាងក្រោម :

- *បង្កើនផលិតភាពកៅស៊ូលើផ្ទៃដីព្រៃដែលត្រូវបានកាប់បំផ្លាញរេចរឹល ក្នុងតំបន់ដីសម្បទាន តាមរយៈការអភិវឌ្ឍន៍ការប្រើប្រាស់ ដំណាំកៅស៊ូជាចំការ និងជាលក្ខណៈកសិ-ឧស្សាហកម្ម។*
- *ពង្រីកគំរបព្រៃដែលបានបាត់បង់ ដោយការកាប់បំផ្លាញអនាធិបតេយ្យកន្លងមក ជំនួសដោយព្រៃកៅស៊ូ សំដៅបរិមាណគំរបព្រៃការពារលំនឹងបរិស្ថានធម្មជាតិ ក្នុងតំបន់ដីសម្បទាន។*
- *រួមចំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ បង្កើនប្រាក់ចំណូលដល់ប្រជាពលរដ្ឋ ពិសេសប្រជាកសិករដែលរស់នៅក្បែរតំបន់វិនិយោគ ក្នុងទិសដៅកាត់បន្ថយភាពក្រីក្រ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។*



Draft

❖ *ជំរុញការកែច្នៃផលិតផលកៅស៊ូសំរាប់ផ្គត់ផ្គង់តំរូវការទីផ្សារក្នុងស្រុក និងធ្វើការនាំចេញទៅទីផ្សារអន្តរជាតិ ។ល ។*

**៣-៥-២ កម្មវត្ថុនៃការប្រើប្រាស់ដីសម្បទាន**

៣១. កម្មវត្ថុនៃការប្រើប្រាស់ដីគំរោងវិនិយោគ សំរាប់ធ្វើវិនិយោគ លើគំរោងបង្កើតកសិកដ្ឋាន ដើម្បីអភិវឌ្ឍន៍ចំការកៅស៊ូ និងការសាងសង់រោងចក្រកែច្នៃ គឺផ្តោតវិនិយោគប្រភេទ ផលិតកម្ម-អាជីវកម្ម ដូចខាងក្រោម :

❖ **ផលិតកម្មចំបង** : ដំណាំកៅស៊ូមានលក្ខណៈជាចំការកសិ-ឧស្សាហកម្ម ទ្រង់ទ្រាយធំ ។

❖ **ផលិតកម្មបន្ទាប់បន្សំ** : ដាំដុះដំណាំរដូវបន្ទាប់បន្សំសំរាប់ជាគំរបដីចន្លោះដើមកៅស៊ូ ដើម្បីទប់ស្កាត់ការហូរច្រោះដី និងបាត់បង់ជីស្រទាប់លើ ។

❖ **ការសាងសង់** : រោងចក្រកែច្នៃផលិតផលកៅស៊ូ ***(នឹងមានលំអិតនៅពេលរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន-សង្គម សម្រាប់គំរោងសាងសង់រោងចក្រកែច្នៃ)*** និងសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ។

**៣-៥-៣ ប្រព័ន្ធនៃការគ្រប់គ្រងដីសម្បទាន**

**៣-៥-៣-១ ទស្សនៈនៃការគ្រប់គ្រងដីសម្បទាន**

**៣២.** <u>ដោយមានកិច្ចសហប្រតិបត្តិការរវាង សាធារណៈរដ្ឋសង្គមនិយមវៀតណាម និងព្រះរាជាណាចក្រកម្ពុជា និងដោយមានការគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា ក្រុមហ៊ុនបានទទួលគោលការណ៍ឯកភាពអនុញ្ញាត ឱ្យធ្វើការវិនិយោគលើផលិតកម្មដំណាំកៅស៊ូក្នុងតំបន់ដីសម្បទាននៃភូមិសាស្ត្រទីកជី ឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ លើផ្ទៃដីសរុបចំនួន **៨.១០០ ហិកតា**</u> ។ ដើម្បីឱ្យគំរោងវិនិយោគនេះ ដំណើរការប្រកបដោយជោគជ័យ ក្រុមហ៊ុនបានសំរេចរៀបចំគំរោងផែនការមេ ដោយផ្អែកលើលក្ខណៈទីតាំងភូមិសាស្ត្រ និងស្ថានភាពដីនៃតំបន់សម្បទាន ។ ទស្សនៈទានរបស់ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ (TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.)** ដែលបានសំរេចដាក់ទុនវិនិយោគនេះគឺ បណ្តាលមកពី:

❖ តំបន់ដីគំរោងវិនិយោគ មានលក្ខណៈអំណោយផលដល់ការដាំដុះដំណាំកៅស៊ូ និងប្រភេទដំណាំកសិ-ឧស្សាហកម្មផ្សេងៗទៀត ។

❖ រាជរដ្ឋាភិបាលកម្ពុជា មានការលើកទឹកចិត្តដល់ការវិនិយោគឯកជនភាវូបនីយកម្ម ពិសេសវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ។

❖ មានកិច្ចសហប្រតិបត្តិការល្អរវាងសាធារណៈរដ្ឋសង្គមនិយមវៀតណាម និងព្រះរាជាណាចក្រកម្ពុជា ។

❖ កំលាំងពលកម្ម និងការចំណាយលើថ្លៃផលិតកម្ម មានកំរិតទាបជាងប្រទេសជិតខាងក្នុងតំបន់ ។



Draft

❖ ជួយធ្វើការអភិវឌ្ឍន៍តំបន់នេះតាមរយៈផ្តល់មុខរបរ និងការងារដល់ប្រជាពលរដ្ឋ ដែលរស់នៅក្បែរតំបន់ដីសម្បទានផ្តល់បច្ចេកវិជ្ជា និងកសាងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដូចជា: ផ្លូវថ្នល់ ប្រព័ន្ធស្រោចស្រព...។ល។ ក្នុងគោលបំណងរួមចំណែកជាមួយរដ្ឋាភិបាលកម្ពុជា ដើម្បីសម្រេចនូវគោលដៅ ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជា និងជំរុញកំណើនសេដ្ឋកិច្ចជាតិ។

❖ ដើម្បីរកប្រាក់ចំណូលជូនក្រុមហ៊ុន ដោយការធ្វើអាជីវកម្មមានលក្ខណៈបច្ចេកទេស និងគិតអំពីលំនឹងបរិស្ថាន ក៏ដូចជាផ្តល់ប្រាក់ចំណូលជូនដល់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈការបង់ពន្ធអាករផ្សេងៗ និងបង្កើនប្រាក់ចំណូលប្រជាពលរដ្ឋកម្ពុជាផងដែរ។

❖ ក្រុមហ៊ុនមានទុនវិនិយោគ និងបទពិសោធន៍គ្រប់គ្រាន់ លើដំណាំកៅស៊ូនៅប្រទេសវៀតណាមម្យ៉ាងវិញទៀត ដើម្បីឈានដល់ការផ្លាស់ប្តូរបទពិសោធន៍បច្ចេកទេសលើវិស័យកសិកម្ម រវាងក្រុមអ្នកបច្ចេកទេសក្រុមហ៊ុនជាមួយនឹងអ្នកបច្ចេកទេសកម្ពុជា។ល។

## ៣-៥-៤ ផែនការនៃការធ្វើអាជីវកម្ម

### ៣-៥-៤-១ ផែនការបែងចែក និងប្រើប្រាស់ផ្ទៃដីសំរាប់ផលិតកម្ម

៣៣. ការកំណត់ផែនការបែងចែកផ្ទៃដីផលិតកម្ម នឹងត្រូវផ្អែកលើលទ្ធផលនៃការអង្កេតធ្វើសារពើភ័ណ្ឌព្រៃឈើធម្មជាតិដែលនៅសេសសល់ក្នុងតំបន់ដីសម្បទាន ដោយផ្តល់នូវទិន្នន័យផ្ទៃដីដែលក្រុមហ៊ុនអាចឈូសឆាយគម្របព្រៃធម្មជាតិ ដែលមិនមានតំលៃសេដ្ឋកិច្ច ដើម្បីដាំដុះដំណាំកៅស៊ូតាមផែនការដាំដុះ។ ផ្ទៃដីដែលមានគម្របព្រៃឈើធម្មជាតិនៅល្អ មានប្រសិទ្ធភាពសេដ្ឋកិច្ច ក្រុមហ៊ុនបានសហការជាមួយក្រុមការងារក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវថែរក្សាការពារមិនធ្វើការឈូសឆាយដាំដុះឡើយ ដោយហេតុនេះហើយ បានជាលើផ្ទៃដីសម្បទានចំនួន ៨.១០០ ហិកតា របស់ក្រុមហ៊ុន ស្ថិតនៅដោយដុំៗពីគ្នាខណ្ឌ ពន្ធ័ដោយតំបន់ព្រៃរក្សាទុក។ ក្រុមហ៊ុនសូមបញ្ជាក់ពីជំហរច្បាស់លាស់ និងរឹងមាំរបស់ក្រុមហ៊ុន លើការគ្រប់គ្រងធ្វើអាជីវកម្ម- ផលិតកម្ម ក្នុងតំបន់ដីសម្បទាន អោយប្រកបដោយចីរភាព និរន្តភាព និង រក្សាបរិស្ថានល្អ។

❖ យោងតាមការសិក្សារបស់ក្រុមការងារក្រសួងសកិកម្ម រុក្ខាប្រមាញ់ និង នេសាទលើកទី១ នាថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០០៧ និង ការសិក្សាលើកទី២ នាថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០៧ របស់ក្រុមការងារក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។

❖ យោងតាមលិខិតលេខ ១៨៨៤ កសក ចុះថ្ងៃទី ០៦ ខែ មករា ឆ្នាំ ២០០៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្នើសុំគោលការណ៍ផ្តល់ដីសម្បទាន ចំនួន ៨.១០០ ហិកតា ទៅទីស្តីការគណៈរដ្ឋមន្ត្រី និង យោងតាមលិខិតលេខ ៥០១ សជណ ចុះថ្ងៃទី១ ខែមករា ឆ្នាំ ២០០៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

ស្តីពីការឯកភាពផ្តល់គោលការណ៍ជូនក្រុមហ៊ុនអោយធ្វើការវិនិយោគ ដាំដំណាំកៅស៊ូលើផ្ទៃដីសម្បទាន ចំនួន ៨.១០០ ហិកតា ។

❖ យោងតាមលិខិតលេខ **២១០៧** កសក ចុះថ្ងៃ ទី ២៣ មេសា ឆ្នាំ ២០០៧ របស់ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ស្នើសុំសិទ្ធប្រទានពីរាជរដ្ឋាភិបាលដើម្បីចុះហត្ថលេខាលើកិច្ចសន្យា ដីសម្បទានចំនួន ៨.១០០ ហិកតា សម្រាប់វិនិយោគលើវិស័យកសិ-ឧស្សាហកម្ម ដាំកៅស៊ូ និងបង្កើតរោងចក្រកែច្នៃ និង យោងតាមលិខិតលេខ ៣៨ ស.ប្រទ ចុះ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការប្រគល់សិទ្ធជូនឯកឧត្តម **ចន្ទ័ សារុន** រដ្ឋមន្រ្តីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដើម្បីចុះហត្ថលេខាលើកិច្ចសន្យាដីសម្បទានចំនួន ៨.១០០ ហិកតា ស្ថិតនៅឃុំក្រយា ស្រុកសន្ទុក ខេត្តកំពង់ធំ សម្រាប់វិនិយោគលើវិស័យកសិ-ឧស្សាហកម្មដាំកៅស៊ូ និងបង្កើតរោងចក្រកែច្នៃ ជាមួយក្រុមហ៊ុន TAN BIEN KAMPONG THOM APHIATH CAOUT CHOUC., LTD ។

❖ ផ្អែកតាមសេចក្តីសម្រេចខាងលើ ក្រុមហ៊ុនបានចុះហត្ថលេខាលើកិច្ចសន្យា ស្តីពីការវិនិយោគលើដាំដំណាំ កសិ-ឧស្សាហកម្មៈ ដាំកៅស៊ូ និងសាងសង់រោងចក្រកែច្នៃ ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ នាថ្ងៃទី ១៨ ខែ កក្កដា ២០០៧ ( ឯកសារជូនភ្ជាប់ក្នុង ឧបសម្ព័ន្ធ ) ។

❖ បច្ចុប្បន្នការបំពេញឯកសារតាមនីតិវិធីត្រូវបានបញ្ចប់ ដូច្នេះទាមទារ ឱ្យក្រុមហ៊ុនអនុវត្តតាមប្រការនៃកិច្ចសន្យានៅថ្ងៃទី ១៨ ខែ កក្កដា ២០០៧ រវាងក្រុមហ៊ុន ជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ។ ចំពោះមុខក្រុមហ៊ុន ត្រូវរៀបចំផែនការមេ លើផ្ទៃដីធនធានសរុបសំរាប់ធ្វើអាជីវកម្ម - ផលិតកម្ម ចំនួន ៨.១០០ ហិកតា ។

**៣៤.** ផែនការមេនេះ នឹងបង្ហាញអំពីការគ្រោងនឹងធ្វើការបែងចែកដីសំរាប់ការដាំដុះ និងការសាងសង់ហេដ្ឋា-រចនាសម្ពន្ធ័ ដូចខាងក្រោម :

| | |
|---|---|
| - ផ្ទៃដីដាំដុះកៅស៊ូ | = ៧.៥៥០ ហិកតា |
| - ផ្ទៃដីសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ | = ៥៥០ ហិកតា |
| **ផ្ទៃដីសរុបរបស់គំរោងវិនិយោគ** | **= ៨.១០០ ហិកតា** |

*( ផ្ទៃដីសម្បទាន ៨.១០០ ហិកតា - ផ្ទៃដីសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ៥៥០ ហិកតា= ៧.៥៥០ ហិកត ជាផ្ទៃដីដាំដុះ)* ។

### ៣-៥-៤-២ ការបែងចែកអនុតំបន់ក្នុងតំបន់ដីសម្បទាន

**៣៥.** ការរៀបចំផែនការមេនេះ គឺក្រុមហ៊ុនរៀបចំ លើទំហំផ្ទៃដីសំរាប់ធ្វើអាជីកម្ម-ផលិតកម្ម ចំនួន ៨.១០០ ហិកតា។ លើផ្ទៃដីនេះក្រុមហ៊ុនធ្វើការបែងចែកជា ០៤ អនុតំបន់ សមរាប់ការធ្វើការដាំដុះ តាមឆ្នាំនិមួយៗ ប៉ុន្តែដោយផ្ទៃដីសម្បទានស្ថិតនៅដាច់ពីគ្នាដោយដុំៗ ក្រុមហ៊ុនធ្វើការបែងចែកជាប្លុកតាមអនុតំបន់

Draft

ណាដែលមានផ្ទៃដីមិនជាប់គ្នា ដូចមានផែនទីជូនភ្ជាប់ ក្នុងគំរោងផែនការមេ ។ ការបែងចែកទំហំផ្ទៃដីសំរាប់ការដាំដុះតាមអនុតំបន់ និង ប្លុកនីមួយៗ មានដូចខាងក្រោម :

**តារាង ៣-១ តារាងប្រើប្រាស់ដីរបស់ក្រុមហ៊ុន តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ**

| ល.រ | លេខអនុតំបន់ | ផ្ទៃដីសំរាប់ដាំដុះ (ហ.ត) | ផ្ទៃដីហេដ្ឋារចនាសម្ព័ន្ធ (ហ.ត) | ផ្ទៃដីសរុប (ហ.ត) |
|---|---|---|---|---|
| ១ | I | ៨៨០ | ១២០ | ១.០០០ |
| ២ | II | ១.៣៧០ | ១៣០ | ១.៥០០ |
| ៣ | III | ២.៤៥០ | ១៥០ | ២.៦០០ |
| ៤ | IV | ២.៨៥០ | ១៥០ | ៣.០០០ |
| **ផ្ទៃដីសរុប** | | **៧.៥៥០** | **៥៥០** | **៨.១០០** |

*កំណត់សំគាល់ : ផ្ទៃដីដាំដុះចំនួន ៧.៥៥០ហ.ត និងផ្ទៃដីសាងសង់ហេដ្ឋារចនាសម្ព័ន្ធចំនួន ៥៥០ហ.ត = ៨.១០០ហិកតា*

- អនុតំបន់ទី I មានផ្ទៃដីធ្វើអាជីវកម្ម -ផលិតកម្មសរុបចំនួន ១.០០០ហិកតា ចែកជា០២ប្លុក គឺ ប្លុក **I.a** មានផ្ទៃដីសរុបចំនួន ៥០០ ហិកតា និង ប្លុក **I.b** មានផ្ទៃដីសរុបចំនួន ៥០០ ហិកតា ។

- អនុតំបន់ទី II មានផ្ទៃដីធ្វើអាជីវកម្ម -ផលិតកម្មសរុបចំនន ១.៥០០ ហិកតា ចែកជា ០៣ប្លុក គឺ : ប្លុក **II.a** មានផ្ទៃដីសរុបចំនួន ៧០០ ហិកតា ប្លុក **II.b** មានផ្ទៃដីសរុបចំនួន ១៥០ ហិកតា ប្លុក **II.c** មានផ្ទៃដីសរុបចំនួន ៦៥០ ហិកតា ។

- អនុតំបន់ទី III មានផ្ទៃដីធ្វើអាជីវកម្ម -ផលិតកម្មសរុបចំនួន ២.៦០០ ហិកតា ចែកជា ០៣ ប្លុក គឺ **III.a** មានផ្ទៃដីសរុបចំនួន ២.២៣០ ហិកតា ប្លុក **III.b** មានផ្ទៃដីសរុបចំនួន ២៧០ ហិកតា ប្លុក **III.c** មានផ្ទៃដីសរុបចំនួន ១០០ ហិកតា .។

- អនុតំបន់ទី IV ជាអនុតំបន់ដែលមានផ្ទៃដីធ្វើអាជីវកម្ម -ផលិតកម្មមានលក្ខណៈប្រមូលផ្តុំ ដូចច្នេះ អនុតំបន់នេះពុំមានការបែងចែកជាប្លុកទេ ។ អនុតំបន់ទី **IV** មានផ្ទៃដីសរុបចំនួន ៣.០០០ ហិកតា ។

អនុតំបន់ និង ប្លុកនិមួយៗមានទំហំផ្ទៃដី និង ព្រំប្រទល់ដូចតទៅ :

- **<u>អនុតំបន់ទី I</u>:** អនុតំបន់ទី I មានផ្ទៃដីធ្វើអាជីវកម្ម -ផលិតកម្មសរុបចំនួន ១.០០០ ហិកតា ចែកជា ០២ ប្លុកមានព្រំប្រទ់ដូចតទៅ :

- ប្លុក **I.a** មានផ្ទៃដីសរុបចំនួន ៥០០ ហិកតា មានព្រំប្រទល់ចាប់ផ្តើមពីចំណុច **F** វត់តាមព្រំប្រទល់ទីសម្បទាន ឬផ្លូវមេព័ន្ធជុំវិញ តំបន់ដីសម្បទានទៅទិសខាងជើង ឈាងខាងកើតដល់ចំណុច **G** ។ ពីចំណុច **G** វត់តាមព្រំប្រទល់ដីសម្បទាន ឬផ្លូវមេព័ន្ធជុំវិញតំបន់ដីសម្បទាន ទៅទិសខាងកើតត្រង់ដល់ចំណុច $A_1$ ។ $A_1$ វត់តាមព្រំប្រទល់តំបន់ដីដកហូត ទៅទិសខាងត្បូងត្រង់ដល់ចំណុច $A_2$ ។ ពីចំណុច $A_2$ វត់តាម

Draft

ព្រំប្រទល់តំបន់ដីដកហូត ទៅទិសខាងកើតត្រង់ដល់ចំណុច **$B_3$** ។ ពីចំណុច **$B_3$** រត់តាមព្រំប្រទល់តំបន់ដីដកហូតទៅទិសខាងត្បូង ត្រង់ដល់ចំណុច **$B_{14}$** ។ ពីចំណុច **$B_{14}$** រត់តាមព្រំប្រទល់តំបន់ដីដកហូត ទៅទិសខាងកើតត្រង់ដល់ចំណុច **$B_{20}$** ។ ពីចំណុច **$B_{20}$** រត់តាមព្រំប្រទល់ដីសម្បទាន ឬ ផ្លូវមេព័ន្ធជុំវិញ តំបន់ដី សម្បទានទៅទិសខាងត្បូងត្រង់ដល់ចំណុច **$C_1$** ។ ពីចំណុច **$C_1$** រត់តាមព្រំប្រទល់ទ្រនាប់ទៅទិសខាងជើងឈាងខាងកើតដល់ចំណុច **$C_2$** ។ ពីចំណុច **$C_2$** រត់តាមព្រំប្រទល់ដីឬ ផ្លូវមេព័ន្ធជុំវិញតំបន់ ដីសម្បទានទៅទិសខាងជើងត្រង់ដល់ចំណុច **F** ដែលជាចំណុចដើមវិញ ។

- ប្លុក **I.b** មានផ្ទៃដីសរុបចំនួន ៥០០ ហិកតា មានព្រំប្រទល់ចាប់ផ្ដើពីចំណុច **$A_2$** រត់តាមពីចំណុចដីសម្បទាន ឬផ្លូវមេព័ន្ធជុំវិញតំបន់ដីសម្បទាន ទៅតិសខាងកើតត្រង់ដល់ចំណុច **E** ។ ពិចំណុច **E** រត់តាមព្រំប្រទល់ដីសម្បទាន ឬផ្លូវមេព័ន្ធជុំវិញតំបន់ដីសម្បទាន ទៅទិសខាងជើងត្រង់ដល់ចំណុច **$C_5$** ។ ពីចំណុច **$C_5$** រត់តាមព្រំប្រទល់តំបន់ទ្រនាប់ ទៅតិសខាងត្បូងឈាងខាងកើតដល់ចំណុច **$C_3$** ។ ពីចំណុច **$C_3$** រត់តាម ផ្លូវមេបែងចែកអនុតំបន់ដិសម្បទាន ទៅទិសខាងលិចត្រង់ដល់ចំណុច **$C_4$** ។ ពិចំណុច **$C_4$** រត់តាមព្រំប្រទល់ទំបន់ទ្រនាប់ទៅទិសខាងជើងត្រង់ដល់ចំណុច **$A_2$** ដែលជាចំណុចដើមវិញ ។ ចំណុចនិយាមកាតាមចំណុចគោលនីមួយៗមានបញ្ជាក់ក្នុងតារាងខាងក្រោម :

**តារាង ៣-១-i : តារាងបញ្ជាក់ពីចំណុចនិយាមកានៃអនុតំបន់ទីI** (ប្លុក I.a )

| ឈ្មោះចំណុច | ចំណុចនិយាមកា | |
|---|---|---|
| | X | Y |
| F | ៥៤៧៩៩១ | ១៣៩១៦៨៧ |
| G | ៥៤៩០៩៥ | ១៣៩១៩៩៨ |
| $A_1$ | ៥៤៩៤៩៩ | ១៣៩២០០៣ |
| $A_{12}$ | ៥៤៩៤៩៩ | ១៣៩១០០៦ |
| $B_3$ | ៥៥០៤៩៧ | ១៣៩០៩៩៥ |
| $B_{14}$ | ៥៥០៤៩៧ | ១៣៩០១៥៧ |
| $B_{20}$ | ៥៥២១២០ | ១៣៩០១៦៧ |
| $C_1$ | ៥៥២១២០ | ១៣៨៨៣០០ |
| $C_2$ | ៥៤៧៩៩៣ | ១៣៩០៤៧៥ |

Draft

**តារាង ៣-១-ii : តារាងបញ្ជាក់ពីចំណុចនិយាមកានៃអនុតំបន់ទីI** (ប្លុក I.b )

| ឈ្មោះចំណុច | ចំណុចនិយាមកា | |
|---|---|---|
| | X | Y |
| $A_2$ | ៥៤៦៦៥៦ | ១៣៨៧៩៩២ |
| E | ៥៤៧៩៩១ | ១៣៨៧៩៩៧ |
| $C_5$ | ៥៤៧៩៩៣ | ១៣៨៩៤២៥ |
| $C_3$ | ៥៥១៤៩៤ | ១៣៨៧៥០៤ |
| $C_4$ | ៥៤៦៦៣៤ | ១៣៨៧៥០៤ |

**-<u>អនុតំបន់ទី II</u>:** អនុតំបន់ទី II មានផ្ទៃដីធ្វើអាជីវកម្ម -ផលិតកម្មសរុបមាន ១.៥០០ ហិកតា ចែកជា ០៣ប្លុកគឺ : ប្លុក II.a ប្លុក II.a និង ប្លុក II.c ដែលមានព្រំប្រទល់ដូចតទៅ :

- ប្លុក II.a មានផ្ទៃដីសរុបចំនួន ៧០០ ហិកតា មានព្រំប្រទល់ចាប់ផ្ដើមពីចំណុច $C_4$ រត់តាមផ្លូវមេបែងចែកអនុតំបន់ដីសម្បទាន ទៅទិសខាងកើតត្រង់ដល់ចំណុច $C_3$ ។ ពីចំណុច $C_3$ រត់តាមព្រំប្រទល់តំបន់ទ្រនាប់ទៅទិសខាងត្បូងឈាងខាងលិចដល់ចំណុច $A_3$ ។ ពីចំណុច $A_3$ រត់តាមផ្លូវមេបែងចែកអនុតំបន់ដីសម្បទាន ទៅទិសខងលិចត្រង់ដល់ចំណុច $A_4$ ។ ពីចំណុច $A_4$ រត់តាមព្រំប្រទល់តំបន់ដីដកហូត ទៅទិសខាងត្បូងឈាងខាងលិចដល់ចំណុច $A_5$ ។ ពីចំណុច $A_5$ រត់តាមព្រំប្រទល់តំបន់ទ្រនាប់ទៅទិសខាងជើងដល់ចំណុច $A_6$ ។ ពីចំណុច $A_6$ រត់តាមព្រំប្រទល់តំបន់ទ្រនាប់ទៅទិសខាងជើងឈាងខាងកើតដល់ចំណុច $C_4$ ដែលជាចំណុចដើមវិញ ។

- ប្លុក II.b មានផ្ទៃដីសរុបចំនួន ១៥០ ហិកតា មានព្រំប្រទល់ចាប់ផ្ដើមពីចំណុច $A_6$ រត់តាមព្រំប្រទល់ដីសម្បទាន ឬផ្លូវមេព័ន្ធជុំវិញតំបន់ដីសម្បទាន ទៅទិសខាងកើតត្រង់ដល់ចំណុច $A_7$ ។ ពីចំណុច $A_7$ រត់តាមព្រំប្រទល់តំបន់ទ្រនាប់ទៅទិសខាងត្បូងឈាងខាងលិចដល់ចំណុច $A_{10}$ ។ ពីចំណុច $A_{10}$ រត់តាមព្រំប្រទល់តំបន់ទ្រនាប់ទៅទិសខាងជើងដល់ចំណុច $A_9$ ។ ពីចំណុច $A_9$ រត់តាមព្រំប្រទល់តំបន់ទ្រនាប់ ទៅទិសខាងជើងឈាងខាងកើតដល់ចំណុច$A_6$ ដែលជាចំណុចដើមវិញ ។

- ប្លុក II.c មានផ្ទៃដីសរុបចំនួន ៦៥០ហិកតា មានព្រំប្រទល់ចាប់ផ្ដើមពីចំណុច A រត់តាមព្រំប្រទល់ដីសម្បទាន ឬ ផ្លូវមេព័ន្ធជុំវិញតំបន់ដីសម្បទាន ទៅទិសខាងជើងត្រង់ឆ្លងកាត់ចំណុច $A_{15}$ ចំណុច $R_1$ និងចំណុច $A_{16}$ ដល់ចំណុច B ។ ពីចំណុច B រត់តាមព្រំប្រទល់ដីសម្បទាន ឬ ផ្លូវមេពន្ធ័ជុំវិញតំបន់ ដីសម្បទាន ទៅទិសខាងកើតត្រង់ដល់ចំណុច $A_{11}$ ។ ពីចំណុច $A_{11}$ រត់តាមព្រំប្រទល់តំបន់ទ្រនាប់ ទៅទិសខាង ត្បូងត្រង់ដល់ចំណុច $A_{13}$ ។ ពីចំណុច $A_{13}$ រត់តាមព្រំប្រទល់ដីសម្បទាន ឬផ្លូវមេព័ន្ធជុំវិញតំបន់ដីសម្បទាន ទៅទិសខាង

Draft

កើតរួចរត់ទៅទិសខាងជើង និងបន្តរត់ទៅទិសខាងលិចត្រង់ រួចបន្តរត់ទៅទិសខាងជើងត្រង់ដល់ ចំណុច $A_{14}$ ។ ពីចំណុច $A_{14}$ រត់តាមព្រំប្រទល់ដីសម្បទាន ឬផ្លូវមេព័ន្ធជុំវិញតំបន់ដីសម្បទាន ទៅទិសខាងជើងឈាងខាងកើតរួចរត់ទៅទិសខាងជើងត្រង់ ហើយបន្តរត់ទៅទិសខាងជើងឈាងខាងលិចដល់ចំណុច A ដែលជាចំណុចដើមវិញ ។ ចំណុចនិយាមការាមចំណុចគោលនិមួយ១ មានបញ្ជាកលក្នុងតារាងចាងក្រោម :

**តារាង៣-១- iii : តារាងបញ្ជាក់ពីចំណុចនិយាមកានៃអនុតំបន់ទី II (ប្លុក II.a )**

| ឈ្មោះចំណុច | ចំណុចនិយាមកា | |
|---|---|---|
| | X | Y |
| $C_4$ | ៥៤៦៦៣៤ | ១៣៨៧៥០៤ |
| $C_3$ | ៥៥១៤៥៤ | ១៣៨៧៥០៦ |
| $A_3$ | ៥៤៨៧៩០ | ១៣៨៥៨១៩ |
| $A_4$ | ៥៤៥៨៧២ | ១៣៨៥៨៤៧ |
| $A_5$ | ៥៤៤២៦៦ | ១៣៨៤៩១២ |
| $A_6$ | ៥៤៤០៨៥ | ១៣៨៥២៦១ |

**តារាង៣-១- iv : តារាងបញ្ជាក់ពីចំណុចនិយាមកានៃអនុតំបន់ទី II (ប្លុក II.b )**

| ឈ្មោះចំណុច | ចំណុចនិយាមកា | |
|---|---|---|
| | X | Y |
| $A_6$ | ៥៤៤០៨៥ | ១៣៨៥២៦១ |
| $A_7$ | ៥៤៥៦៣៤ | ១៣៨៧៩៥៧ |
| $A_{10}$ | ៥៤៣៩៥៤ | ១៣៨៦២៨៣ |
| $A_9$ | ៥៤៣៩៣១ | ១៣៨៧៣៤១ |

**តារាង៣-១- v : តារាងបញ្ជាក់ពីចំណុចនិយាមកានៃអនុតំបន់ទី II (ប្លុក II.c )**

| ឈ្មោះចំណុច | ចំណុចនិយាមកា | |
|---|---|---|
| | X | Y |
| A | ៥៤១៩៩០ | ១៣៨១៨៩២ |
| $A_{15}$ | ៥៤១៩៩១ | ១៣៨៣០៤៣ |

Draft

| | | |
|---|---|---|
| $R_1$ | ៥៤១៩៨៩ | ១៣៨៣៩៩៩ |
| $A_{18}$ | ៥៤៤៧៥១ | ១៣៨១១៦៩ |
| B | ៥៤១៩៥០ | ១៣៨៧៥១៤ |
| $A_{11}$ | ៥៤២៨០០ | ១៣៨៧៥០៩ |
| $A_{13}$ | ៥៤៣៨៣៩ | ១៣៨២១៦៨ |
| $A_{14}$ | ៥៤២៧១៤ | ១៣៨០៧២០ |

- **<u>អនុតំបន់ទី III</u> :** អនុតំបន់ទី **III** មានផ្ទៃដីធ្វើអាជីវកម្ម-ផលិតកម្មសរុបចំនួន ១.៥០០ ហិកតា ចែកជា០៣ប្លុកគឺ : ប្លុក III.a ប្លុក III.b និង ប្លុក II.c ដែលមានព្រំប្រទល់ដូចតទៅ :

- ប្លុក III .a មានផ្ទៃដីសរុបចំនួន ២.២៣០ ហិកតា មានព្រំប្រទល់ចាប់ផ្តើមពីចំណុច $B_1$ រត់តាមផ្លូវមេបែងចែលអនុតំបន់ដីសម្បទានទៅទិសខាងកើតត្រង់ដល់ចំណុច $B_{17}$ ។ ពីចំណុច $B_{17}$ រត់តាមព្រំប្រទល់ដីសម្បទាន ឬតាមផ្លូវមេព័ន្ធជុំវិញតំបន់ដីសម្បទាន ទៅទិសខាងជើងត្រង់ឆ្លងកាត់ចំណុច $R_3$ រួចបន្តរត់ទៅទិសខាងជើងត្រង់ដល់ចំណុច J ។ ពីចំណុច J រត់តាមព្រំប្រទល់ដីសម្បទាន ឬតាមផ្លូវមេព័ន្ធជុំវិញ តំបន់ដីសម្បទានទៅទិសខាងលិចត្រង់ដល់ចំណុច I ។ ពី ចំណុច I រត់តាមព្រំប្រទល់ដីសម្បទាន ឬតាមផ្លូវមេព័ន្ធជុំវិញតំបន់ដីសម្បទាន ទៅទិសខាងជើងត្រង់ដល់ចំណុច $B_7$ ។ ពីចំណុច $B_7$ រត់តាមព្រំប្រទល់ តំបន់ទ្រនាប់ទៅទិសខាងត្បូងឈាងខាងលិចដល់ចំណុច $B_6$ ។ ពីចំណុច $B_6$ រត់តាមផ្លូវមេក្នុងតំបន់ដីសម្បទាន ទៅទិសខាងត្បូងត្រង់ដល់ចំណុច $R_2$ ។ ពីចំណុច $R_2$ រត់តាមព្រំប្រទល់តំបន់ដីដកហូត ទៅទិសខាងជើងត្រង់ដល់ចំណុច $B_5$ ។ ពីចំណុច $B_5$ រត់តាមព្រំប្រទល់តំបន់ដីដកហូត ទៅទិសខាងកើតត្រង់ចំណុច $B_4$ ។ ពីចំណុច $B_4$ រត់តាមព្រំប្រទល់តំបន់ទ្រនាប់ទៅទិសខាងជើងត្រង់ដល់ចំណុច $B_2$ ។ ពីចំណុច $B_2$ រត់តាមផ្លូវមេពទ្ធ័ជុំវិញតំបន់ដីសម្បទានទៅទិសខាងកើតត្រង់ឆ្លងកាត់ចំណុច $B_{11}$ ចំណុច $B_{10}$ រួចបន្តរត់ទៅទិសខាងកើតត្រង់ដល់ចំណុច N ។ ចំណុច N រត់តាមព្រំប្រទល់តំបន់ទ្រនាប់ ទៅទិសខាងជើងឈាងខាងលិចដល់ចំណុច $B_1$ ដែលជាចំណុចដើមវិញ ។

- ប្លុក III.b មានផ្ទៃដីសរុបចំនួន ២៧០ហិកតា មានព្រំប្រទល់ជាប់ចាប់ផ្តើមពីចំណុច $A_{19}$ រត់តាមព្រំប្រទល់ដីសម្បទាន ឬផ្លូវមេព័ន្ធជុំវិញតំបន់ដីសម្បទាន ទៅទិសខាងកើតដល់ចំណុច $A_{18}$ ។ ពីចំណុច $A_{18}$ រត់តាមព្រំប្រទល់ដីសម្បទាន ឬផ្លូវមេព័ន្ធជុំវិញតំបន់ដីសម្បទាន ទៅទិសខាងកើតដល់ចំណុច $A_{17}$ ។ ពីចំណុច $A_{17}$ រត់តាមព្រំប្រទល់ដីសម្បទាន ឬផ្លូវមេព័ន្ធជុំវិញតំបន់ដីសម្បទាន ទៅទិសខាងកើតដល់ចំណុច O ។ ពីចំណុច O រត់តាមព្រំប្រទល់តំបន់ទ្រនាប់ ទៅទិសខាងជើងត្រង់ដល់ចំណុច $A_{20}$ ។ ពីចំណុច $A_{20}$ រត់តាមព្រំប្រទល់តំបន់ទ្រនាប់ទៅទិសខាងត្បូងត្រង់ដល់ចំណុច $A_{19}$ ដែលជាចំណុចដើមវិញ ។

Draft

- ប្លុក III.c មានផ្ទៃដីសរុបចំនួន ១០០ ហិកតា មានព្រំប្រទល់ជាប់ចាប់ផ្ដើមពីចំណុច $A_4$ វត់តាមផ្លូវមេបែងចែកអនុតំបន់ដីសម្បទាន ទៅទិសខាងកើតត្រង់ដល់ចំណុច $A_3$ ។ ពីចំណុច $A_3$ វត់តាមព្រំប្រទល់តំបន់ទ្រនាប់ ទៅទិសខាងត្បូងត្រង់ដល់ចំណុច $B_{12}$ ។ ពីចំណុច $B_{12}$ វត់តាមព្រំប្រទល់ទំបន់ដីដកហូត ទៅទិសខាងលិចឈាងខាងជើងដល់ចំណុច $A_4$ ដែលជាចំណុចដើមវិញ។ ចំណុចនិយាមការតាមចំណុចគោលនីមួយៗ មានបញ្ជាក់ក្នុងតារាងខាងក្រោម :

**តារាង ៣-១-vi: តារាងបញ្ជាក់ពីចំណុចនិយាមកានៃអនុតំបន់ទី III** (ប្លុក III .a )

| ឈ្មោះចំណុច | ចំណុចនិយាមកា | |
|---|---|---|
| | X | Y |
| $B_1$ | ៥៤៥៨៧៧ | ១៣៨៣១៨២ |
| $B_{17}$ | ៥៥៧០៦៩ | ១៣៨៣០០១ |
| $B_3$ | ៥៥៧១០៥ | ១៣៨៤០០៣ |
| J | ៥៥៧១៣១ | ១៣៨៥៩០០ |
| I | ៥៤២១២៤ | ១៣៨៥៩០០ |
| $B_7$ | ៥៥២១១៥ | ១៣៨៦២៦៦ |
| $B_6$ | ៥៤៨៦៨២ | ១៣៨៤៧៧០ |
| $R_2$ | ៥៤៨៤៩៩ | ១៣៨៤០០១ |
| $B_5$ | ៥៥៤៩៩៩ | ១៣៨៤០០៤ |
| $B_4$ | ៥៤៨៥០១ | ១៣៩១៨៣០ |
| $B_2$ | ៥៤៦៩៣៣ | ១៣៨១៩៩២ |
| $B_{11}$ | ៥៤៧៨៩៨ | ១៣៨២០០៤ |
| $B_{10}$ | ៥៤៩០៧៥ | ១៣៨១៩៩២ |
| N | ៥៤៩៩៩១ | ១៣៨១៩៩៦ |

Draft

**តារាង ៣-១-vii: តារាងបញ្ជាក់ពីចំណុចនិយាមកានៃអនុតំបន់ទី III** (ប្លុក III .b )

| ឈ្មោះចំណុច | ចំណុចនិយាមកា | |
|---|---|---|
| | X | Y |
| $A_{19}$ | ៥៨៤៣៩៣ | ១៣៨១៧១៣ |
| $A_{18}$ | ៥៨៤៧៥១ | ១៣៨១១៦៩ |
| $A_{17}$ | ៥៨៥៦១១ | ១៣៨១២០៣ |
| O | ៥៨៥៩៩១ | ១៣៨១៩៩៦ |
| $B_1$ | ៥៨៥៨៧៧ | ១៣៨៣១៨២ |
| $A_{20}$ | ៥៨៤៤០៨ | ១៣៨៣១៦៧ |

**តារាង ៣-១-viii: តារាងបញ្ជាក់ពីចំណុចនិយាមកានៃអនុតំបន់ទី III** (ប្លុក III .c )

| ឈ្មោះចំណុច | ចំណុចនិយាមកា | |
|---|---|---|
| | X | Y |
| $B_1$ | ៥៨៥៨៧៧ | ១៣៨៣១៨២ |
| $B_{17}$ | ៥៩៧០៦៩ | ១៣៨៣០០១ |
| $B_3$ | ៥៩៧១០៥ | ១៣៨៤០០៣ |

- **__អនុតំបន់ទី IV__ :** អនុតំបន់ទី IV មានផ្ទៃដីសរុបចំនួន ៣.000 ហិកតា អនុតំបន់នេះផ្ទៃដីមានលក្ខណៈប្រមូលផ្តុំ ដូច្នេះក្នុងអនុតំបន់ពុំមានការបែងចែកជាប្លុកទេ។ អនុតំបន់ទី IV មានព្រំប្រទល់ចាប់ផ្តើមពីចំណុច K រត់តាមព្រំប្រទល់ដីសម្បទាន ឬផ្លូវមេព័ទ្ធជុំវិញតំបន់ដីសម្បទាន ទៅទិសខាងជើងត្រង់ ឆ្លងកាត់ចំណុច $R_8$ រួចរត់បន្តទៅទិសខាងជើងត្រង់ដល់ចំណុច $B_{17}$។ ពីចំណុច $B_{17}$ រត់តាមផ្លូវមេបែងចែកអនុតំបន់ដីសម្បទាន ទៅទិសខាងលិចដល់ចំណុច $B_1$។ ពីចំណុច $B_1$ រត់តាមព្រំប្រទល់តំបន់ទ្រនាប់ ទៅទិសខាងត្បូងឈៀងខាងកើតដល់ចំណុច$B_{18}$។ ពីចំណុច $B_{18}$ រត់តាមព្រំប្រទល់ដីសម្បទាន ឬផ្លូវមេព័ទ្ធជុំវិញតំបន់ដីសម្បទាន ទៅទិសខាងត្បូងដល់ចំណុច M។ ពីចំណុច M រត់តាមព្រំប្រទល់ដីសម្បទាន ឬផ្លូវមេព័ទ្ធជុំវិញតំបន់ដីសម្បទាន ទៅទិសខាងត្បូងឈៀងខាងកើត ឆ្លងកាត់ចំណុច $B_{13}$ ចំណុច $R_6$ និងចំណុច $B_{15}$ រួចបន្តរត់ទៅ ទិសខាងត្បូងឈៀងខាងកើតដល់ចំណុច L។ ពីចំណុច L រត់តាមព្រំប្រទល់ដីសម្បទាន ឬផ្លូវមេព័ទ្ធជុំវិញតំបន់ដីសម្បទាន ទៅទិសខាងជើងឈៀងខាងកើតដល់ចំណុច K ដែលជាចំណុចដើមវិញ។ ចំណុចនិយាមការតាម ចំណុចគោលនីមួយៗ មានបញ្ជាក់ក្នុងតារាងខាងក្រោម :

Draft

**តារាង ៣-១-xi: តារាងបញ្ជាក់ពីចំណុចនិយាមកានៃអនុតំបន់ទី IV**

| ឈ្មោះចំណុច | ចំណុចនិយាមកា | |
|---|---|---|
| | X | Y |
| K | ៥៥៤៨៨៩ | ១៣៧៧៩៩៥ |
| $R_8$ | ៥៥៧១១២ | ១៣៨០៩៩៤ |
| $B_{17}$ | ៥៥៧០៦៩ | ១៣៨៣០០១ |
| $B_1$ | ៥៤៥៨៧៧ | ១៣៨៣១៨២ |
| $B_{18}$ | ៥៤៩៩៨៩ | ១៣៨០៤១២ |
| M | ៥៤៩៩៩១ | ១៣៧៩៩៩៦ |
| $B_{13}$ | ៥៥៣៦៣១ | ១៣៧៧៤១៧ |
| $R_6$ | ៥៥៦០០២ | ១៣៧៧១៤៦ |
| $B_{15}$ | ៥៥៤៤៨៤ | ១៣៧៦៨១៥ |
| L | ៥៥៤៨៨៩ | ១៣៧៦៥១២ |

**បញ្ជាក់** : *ទំហំផ្ទៃដីដែលបញ្ជាក់ពីអនុតំបន់នីមួយៗ គឺជាទំហំផ្ទៃដីសំរាប់ធ្វើការដាំដុះ និង ធ្វើអាជីវកម្ម - ផលិតកម្ម (ឧបសម្ព័ន្ធ ៣-២ : តារាងឧបសម្ព័ន្ធទី-១ក ជូនភ្ជាប់) ក្រុមហ៊ុនគ្រោងផែនការដាំដុះដូចតទៅ : ឆ្នាំទី១ ធ្វើការដាំដុះ ក្នុងអនុតំបន់ I ឆ្នាំទី២ ធ្វើការដាំដុះក្នុងអនុតំបន់ II ឆ្នាំទី៣ ធ្វើការដាំដុះក្នុងអនុតំបន់ III ឆ្នាំទី៤ ធ្វើការ ដាំដុះក្នុងអនុតំបន់IV និង ឆ្នាំទី៥ ធ្វើការដាំដុះក្នុងអនុតំបន់ V ។*

*- អនុតំបន់ I អនុតំបន់ II អនុតំបន់ III មានធ្វើការបែងចែកជាប្លុកព្រោះអនុតំបន់នេះផ្ទៃដីស្ថិតនៅដាច់ដោយដុំៗ ខណ្ឌ័ព័ទ្ធដោយតំបន់ទ្រនាប់ តំបន់ដកតាមដីការ និង តំបន់បំរុងទុក ។ ដោយឡែកអនុតំបន់ទី IV មិនធ្វើការបែងចែកជាប្លុកទេ ព្រោះផ្ទៃដីអនុតំបន់នេះ មានលក្ខណៈប្រមូលផ្តុំ (ផែនទីជូនភ្ជាប់ក្នុងឧបសម្ព័ន្ធ) ។*

*- ក្រុមហ៊ុនគ្រោងផ្ទៃដីចំនួន ៥៥០ ហិកតា សំរាប់សំណង់ផ្សេងៗដូចជា រោងចក្រ ទីស្នាក់ការ លំនៅដ្ឋាន ឃ្លាំង ប្រព័ន្ធផ្លូវ ប្រព័ន្ធស្រោចស្រព..... ។ល។*

### ៣-៥-៥ ការរៀបចំដីដើម្បីដាំកៅស៊ូ

### ៣-៥-៥-១ ការឈូសឆាយព្រៃ ឬការរំលំឈើ

**៣៦.** ការឈូសព្រៃ ឬការរំលំឈើអាចដំណើរការបាន ដោយការប្រើនូវប្រភេទគ្រឿងចក្រមួយចំនួន ដូចជា Bulldozers, Excavators… ។ល។ ប្រតិបត្តិការឈូសឆាយព្រៃ ឬការរំលំឈើ នេះចាំបាច់ត្រូវធ្វើឡើងនៅក្នុងរដូវគ្មានភ្លៀងដើម្បីកាត់បន្ថយផលប៉ះពាល់ទៅលើបញ្ហាបរិស្ថាន។ រដូវកាលដែលសមស្របសម្រាប់ប្រតិបត្តិការ

Draft

នេះគឺត្រូវចាប់ពីចុងខែតុលា ហើយបន្តរហូតដល់ចុងខែមេសា ឬឆ្នាំខ្លះអាចអូសបន្លាយរហូតដល់ចុងសប្តាហ៍ទី-២ ឬពាក់កណ្តាលសប្តាហ៍ទី-៣ នៃខែឧសភា។ ដីដែលជាំទឹក ឬជាដីព្រៃដែលមានប្រព័ន្ធផ្លូវទឹក (ដៃអូរ ឬអូរតូចៗ) ដែលគ្មាននៅក្នុងផែនទី ឬកន្លែងដែលមានថ្មាំងថ្មធំក្រាស់ផុសនៅលើផ្ទៃដី ត្រូវបន្សល់ទុកដោយមិនធ្វើការឈូសឆាយទេ ព្រោះនឹងនាំមកនូវផលប៉ះពាល់បរិស្ថាន និងមិនអាចធ្វើការដាំដំណាំកៅស៊ូបាន។

## ៣-៥-៥-២ ការកាត់ និងដឹកជញ្ជូនឈើ

៣៧. ក្រោយពីការឈូសរំលំរួចហើយ ឈើទាំងអស់ (ដែលមានអង្កត់ផ្ចិតពី៩ស.មឡើងទៅគោលការណ៍ណែនាំថ្មីរបស់ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ) ត្រូវធ្វើការកាត់ (Logs' Extraction) ដែលការកាត់យកឈើដែលអាចប្រើប្រាស់បាននេះ ត្រូវអនុវត្តទៅតាមក្រមបច្ចេកទេសប្រមូលផលព្រៃឈើកម្ពុជា ឬគោលការណ៍ណែនាំថ្មីៗ (បទដ្ឋានបច្ចេកទេស) របស់ក្រសួងកសិកម្ម។

៣៨. ឈើដែលកាត់ហើយត្រូវដឹកជញ្ជូនទៅកាន់គំនរឈើ ដោយត្រូវគរទុកទៅតាមប្រភេទនៃចំណាត់ថ្នាក់ប្រភេទឈើដែលត្រូវបង់ពន្ធ។ ឧទាហរណ៍ ឈើប្រណិត ឈើលេខ-១ ឈើលេខ-២ ឈើលេខ-៣ និងឈើក្រៅលំដាប់ថ្នាក់ ត្រូវគរទុកដោយឡែកៗ និងមានសណ្តាប់ធ្នាប់ ដើម្បីបង្កលក្ខណៈងាយស្រួលអោយមន្ត្រីរដ្ឋបាលព្រៃឈើសង្កាត់ ខេត្ត និងសមត្ថកិច្ចជំនាញរបស់អង្គភាពពាក់ព័ន្ធ សហការជាមួយសាម៉ីក្រុមហ៊ុនធ្វើការវាស់វែង និងបង់ពន្ធសួយសារផ្សេងៗ ចូលទៅក្នុងថវិការដ្ឋ។

## ៣-៥-៥-៣ ការធ្វើអនាម័យដី

៣៩. កាកសំណល់ឈើ (គល់ ឫស ចុង និងមែក) ដែលនៅសេសសល់ត្រូវធ្វើការសំអាត តាមរយៈការប្រមូលគរទុកជាពុំនូកៗ រងចាំស្ងួតល្អត្រឹមត្រូវ ហើយធ្វើការដុតចោល។ វិធីសាស្ត្រនេះងាយស្រួល ហើយអស់លុយតិច តែបង្កអោយមានផលប៉ះពាល់បន្ទាប់បន្សំគួរតែយកចិត្តទុកដាក់ ប្រសិននៅទូទាំងតំបន់អនុវត្តនូវទំនៀមទំលាប់នេះដូចៗគ្នា។

## ៣-៥-៥-៤ ការភ្ជួរដី

៤០. ការភ្ជួរដីចែកចេញជាពីរវគ្គសំខាន់គឺ: (១) **<u>ការភ្ជួរដីដោយប្រើផាលបី:</u>** ការភ្ជួរដោយប្រើផាលបីធ្វើឡើងក្នុងគោលបំណងសំអាតដីអោយបានកាន់តែស្អាត (ឬដែលនៅសេសសល់តូចៗល្មម) អាចធ្វើការប្រមូលបន្ថែមជាលើកចុងក្រោយ។ ការភ្ជួរប្រមូលយកឫសចេញចុងក្រោយនេះនឹងជួយកាត់បន្ថយការដុះ (លាស់) ល្បាស់ឈើ ដែលជាលទ្ធផលអាចជួយកាត់បន្ថយការងារថែទាំក្រោយពេលដាំដុះ បានយ៉ាងច្រើន និង (២) **<u>ការភ្ជួរដោយប្រើផាលប្រាំពីរ:</u>** ការភ្ជួរដោយប្រើផាលប្រាំពីរគឺជាការភ្ជួរសំអាតដីចុងក្រោយ មុនពេលដៅរណ្តៅ

កៅស៊ូ ឬមុនពេលធ្វើការខួងរណ្តៅសម្រាប់ដាក់ដាំកូនកៅស៊ូ។ ការភ្ជួរទាំងពីរលើកនេះ ត្រូវចាប់ផ្តើមឡើងបន្តបន្ទាប់គ្នានៅដើមរដូវវស្សា (ក្រោយវិសាខបូជា ឬនៅដើមខែប្រាំ អាស្រ័យនឹងកំរិតនៃសំណើមរបស់ដី)។

### ៣-៥-៦ ការដាំដុះកៅស៊ូ

៤១. បច្ចុប្បន្ននេះ ការដាំដុះកៅស៊ូដោយគ្រាប់ផ្ទាល់នៅឡូតិ៍ចំការមិនត្រូវបានយកមកអនុវត្តទៀតទេ។ ព្រោះការដាំបែបនេះ ធ្វើអោយចុះកម្លាំងពលកម្មច្រើន ហើយធ្វើការបំបៅ និងថែទាំកូនពូជមិនបានល្អ ដែលជាលទ្ធផល ធ្វើអោយអត្រានៃការងាប់របស់កូនកៅស៊ូមានកំរិតខ្ពស់។ បច្ចុប្បន្ន កូនកៅស៊ូត្រូវបានគេបំបៅហើយប្រមាណជាមួយឆ្នាំនៅក្នុងថ្នាល ឬច្បារពូជជាសិនមុននឹងយកទៅដាំនៅក្នុងចំការ។

#### ៣-៥-៦-១ ការរៀបចំច្បារពូជ

៤២. ច្បារពូជជាកន្លែងផលិតមេពូជ សំរាប់យកទៅបំបៅលើកូនកៅស៊ូនៅថ្នាលបណ្តុះកូន។ ដូចនេះដើម្បីទទួលបានមែកពូជ ចាំបាច់ត្រូវរៀបចំច្បារពូជនៅលើផ្ទៃដីមួយ ដែលមានបរិមាណសមស្របគ្រប់គ្រាន់ដែលត្រូវផ្តល់ឱ្យដល់រដូវបំបៅ។ ដូច្នេះច្បារពូជត្រូវបង្កើតឱ្យបានមុន០១ឆ្នាំ មុនការដាំកៅស៊ូ។

៤៣. កូនកៅស៊ូដែលបំបៅហើយ ត្រូវដាក់ក្នុងចន្លោះពីគុម្ពមួយទៅគុម្ពមួយ (នៅលើផ្ទៃដី) ទំហំ១ម$^{២}$ ឬមានចំនួនស្មើនឹង១០.០០០គុម្ព ក្នុងមួយហិកតា។ ជាធម្មតាច្បារពូជទំហំ១ហិកតា អាចផ្តល់ភ្នែកសម្រាប់បំបៅកូនកៅស៊ូយកទៅដាំដុះលើផ្ទៃដីប្រមាណ២០០ហិកតាបាន ដោយអាស្រ័យជាមួយនឹងភាពប៉ិនប្រសព្វរបស់អ្នកបំបៅ និងការថែទាំ។

#### ៣-៥-៦-២ ការជ្រើសរើសទីតាំង

៤៤. ការជ្រើសរើសទីតាំង គឺមានសារៈសំខាន់សំរាប់ការរៀបចំច្បារពូជ។ ទីតាំងច្បារពូជត្រូវស្ថិតឱ្យឆ្ងាយពីទីតាំងចំការចាស់ ឬឡូតិ៍ចំការចាស់ដែលកាប់ចោលយូរ។ ទិសនៃរង និងជួរដើមនៃច្បារពូជ ត្រូវរៀបចំឡើងពីទិសខាងកើត-លិច ឬត្បូងឆៀងខាងលិច តាមទិសខ្យល់មូសុងវស្សារៀងរាល់ឆ្នាំដាំដុះនិមួយៗ។

#### ៣-៥-៦-៣ ប្រភេទភ្នែកបំបៅ

៤៥. ផ្នែកកៅស៊ូដែលត្រូវបំបៅមានពីរប្រភេទគឺ: (១) **ភ្នែកពណ៌ត្នោត:** ភ្នែកពណ៌ត្នោតគឺជាភ្នែកចាស់កូនពូជប្រភេទនេះមានដុះសាច់ឈើរួចហើយ ហើយជាធម្មតាកូនពូជបែបនេះមានអាយុចន្លោះពី១០-២០ខែ។ ការបំបៅភ្នែកពណ៌ត្នោតនេះ ត្រូវបានគេនិយមប្រើប្រាស់យ៉ាងទូលំទូលាយតាំងពីយូរយារណាស់មកហើយ និង (២) **ភ្នែកពណ៌បៃតងខ្ចី:** ភ្នែកពណ៌បៃតងជាភ្នែកខ្ចី ព្រោះកូនពូជមិនទាន់ដុះសាច់ឈើនៅឡើយទេ កូនពូជប្រភេទនេះ ទើបតែមានអាយុបានប្រមាណចន្លោះពី៣-៤ខែប៉ុណ្ណោះ។ លក្ខណៈពិសេសនៃការបំបៅភ្នែកពណ៌

Draft

បៃតង គឺកូនដែលបំបៅហើយឆាប់មានសុខភាព និងមានការលូតលាស់ជាងភ្នែកពណ៌ត្នោត តែការបំបៅភ្នែកប្រភេទនេះទាមទារអោយអ្នកបំបៅមានបទពិសោធន៍ និងមានការយកចិត្តទុកដាក់ខ្លាំងណាស់។

### ៣-៥-៦-៤ ការគ្រប់គ្រងច្បារពូជ

៤៦. ទិដ្ឋភាពសំខាន់នៃការគ្រប់គ្រងច្បារពូជ គឺរក្សាទុកនូវភាពសុទ្ធនៃរុក្ខសំភារៈ នឹងធានាផ្គត់ផ្គង់ឱ្យបានទាំងគុណភាព និងភាពក្មេងខ្ចីនៃមែកពូជដើម្បីបំរើដល់ការបំបៅ។

**៤៧. ប្រភេទពូជ (ក្លូន) ត្រៀមដាំ :** *ពូជត្រៀមដាំ (ក្លូន) GT1; PB260; RRIM600; IRCA230; PB217; IRCA18; RRIC100; PB235; IRCA130; KV4; VM 515 ដែលនាំមកពីប្រទេសវៀតណាម។*

### ៣-៥-៦-៥ ការរៀបចំថ្នាល និងការបណ្ដុះកូនកៅស៊ូ

៤៨. ថ្នាលបណ្ដុះកូនត្រូវមានលក្ខណៈប្រមូលផ្តុំ ដើម្បីងាយស្រួលក្នុងការថែទាំ និងការពារសត្វចង្រៃ-ជំងឺដល់កូនកៅស៊ូ ក្នុងគោលបំណងទទួលបាននូវកូនកៅស៊ូដែលមានសុខភាពមាំមួនល្អ ធន់នឹងកត្តាខាងក្រៅ ឆាប់ដុះឫស និងលូតលាស់លឿន ពេលគាស់យកទៅដាំនៅតាមឡូតិ៍ចំការក្នុងអនុតំបន់។ ត្រូវរៀបចំដីសម្រាប់បណ្ដុះកូនកៅស៊ូចូលទៅក្នុងថង់កៅស៊ូ (ប៉ូលីអេទីឡែន - ទំហំ៣០ស.ម × ៤០ស.ម) មានទំងន់ប្រមាណពី ១០-១៥ គ.ក្រ ហើយកប់គ្រាប់កៅស៊ូដែលពាកពន្លកហើយ (ជម្រៅប្រមាណ១០ស.ម) ចំនួនពីរគ្រាប់ចូលទៅចូលទៅក្នុងថង់។ ត្រូវចោះប្រហោងនៅតាមបាតថង់ ដើម្បីឱ្យឫសចាក់ទំលុះចេញស្រួល និងមានប្រហោងតូចៗ នៅផ្នែកចំហៀងដើម្បីរំដោះទឹកចេញ។ ពេលកូនកៅស៊ូដុះ (ជ្រើសរើសយកកូនណាមួយដែលមានសុខភាពល្អជាងគេ) សមល្មមសម្រាប់ធ្វើការបំបៅ ហើយចាំបាច់ត្រូវធ្វើការបំបៅ ដោយរង់ចាំអោយកូនបំបៅនេះដុះលូតលាស់បានរឹងមាំជាមុនសិន ទើបយកទៅដាំក្នុងឡូតិ៍ចំការ។ ថ្នាលមួយហិកតាអាចបណ្ដុះកូនដើម្បីយកទៅផលិតជាកូនបំបៅសំរាប់ដាំនៅលើចំការបានចំនួន ១០០ហិកតា។

### ៣-៥-៦-៦ ការជ្រើសរើសទីតាំង

៤៩. ទីតាំងដែលត្រូវជ្រើសរើសសម្រាប់រៀបចំថ្នាលបណ្ដុះកូនកៅស៊ូ ត្រូវនៅជិតប្រភពទឹកសំរាប់ស្រោចស្រព មានសណ្ឋានដីរាបស្មើមិនដក់ទឹក និងមានជំរៅដីប្រហែល ០១ម៉ែត្រ គឺសមស្របល្អសំរាប់ថ្នាលបណ្ដុះកូន។

### ៣-៥-៦-៧ ការរៀបថ្នាលសំរាប់បណ្ដុះកូនកៅស៊ូ

៥០. ត្រូវធ្វើដីឱ្យរាបស្មើ មានប្រឡាយបង្ហូរទឹកដែលមានទទឹង ៣០ស.ម និងជម្រៅ៣០ស.ម មិនដក់ទឹក និងត្រូវមានផ្លូវសំរាប់ការងារថែទាំ (ការដាក់ជី បោចស្មៅ បង្ការជំងឺ ស្រោចទឹក ការបំបៅ) និងការត្រួតពិនិត្យការលូតលាស់ ក៏ដូចជាសំរួលដល់ចលនាខ្យល់ និងពន្លឺដល់កូនកៅស៊ូផងដែរ។ ត្រូវរៀបចំដីឱ្យបានត្រឹមត្រូវដោយការកាយសសុះដីអោយបានជម្រៅ ៦០-១០០ស.ម ដើម្បីបង្កការងាយស្រួលដល់កូនកៅស៊ូចាក់ឫស។៣-

### ៣-៥-៦-៨ ការរៀបចំឡូត៍ចំការកៅស៊ូ និងដង់ស៊ីតេដើមកៅស៊ូ

**៥១.** ធ្វើការត្រួតពិនិត្យ កសាងគំរោងការគ្រប់ផ្នែក និងត្រូវធ្វើឱ្យបានហ្មត់ចត់នូវបណ្តាលក្ខខ័ណ្ឌធានាដល់កសិដ្ឋាន និងមានប្រសិទ្ធិភាពសេដ្ឋកិច្ចខ្ពស់។ ត្រូវបែងចែកឱ្យបានច្បាស់នូវប្រភេទដីដែលមិនអាចដាំកៅស៊ូបាន (ស្រែ ដីជាំទឹក ប្រលាយ ដីចំណោតខ្លាំង និងដីមានក្រួសថ្មច្រើន) ដើម្បីទុកក្នុងពេលបែងចែកឡូត៍។ ការគាស់រានរៀបចំដីចែកជាក្បាលដីរាងការ៉េមានទំហំ ១០០ហិកតា ដោយរៀបចំបែងចែកក្បាលដីអោយបានត្រង់ប្រសិនបើរាបស្មើ។ ក្នុងក្បាលដីនីមួយៗ ត្រូវបែងចែកជា៤ឡូត៍ ដែលក្នុងមួយឡូត៍មាន២៥ហិកតា។ ការឆ្ការព្រៃត្រូវធ្វើនៅរដូវប្រាំង ដើម្បីដាំឱ្យទាន់នៅក្នុងរដូវភ្លៀង ហើយស៊ីសង្វាក់ជាមួយនឹងការងារផលិតកូនកៅស៊ូ (បំបៅ) ជៀសវាងទុកដីឱ្យនៅទំនេរ ងាយរងនូវសំណឹក និងការហូរច្រោះ។ ការរៀបចំដីត្រូវធ្វើឱ្យបានត្រឹមត្រូវ ដើម្បីចៀសវាងនូវជំងឺឫស និងការហូរច្រោះដី។ ការសំរេចអោយបាននូវជួរកៅស៊ូត្រង់ល្អ គឺជាទិដ្ឋភាពសំខាន់បំផុតក្នុងការដាំដុះកៅស៊ូ។ ការគាស់គល់ ចាំបាច់ត្រូវគាស់ឫសចេញអោយអស់ រាល់បំណែកនៃគល់ត្រូវប្រមូលដុតនៅនឹងកន្លែង។ ការងារនេះត្រូវអនុវត្តក្នុងកំឡុងពេលខ្យល់មូសុងឦសាន្ត ពោលគឺក្នុងពេលដីចាប់ផ្តើមស្ងួត បង្កការងាយស្រួលដល់ការគាស់ឫស ហើយជួយលុបបំបាត់ប្រព័ន្ធឫសបានទាំងស្រុង។

**៥២.** ទំហំរងដែលកំណត់សម្រាប់ការដាំគឺ ពីជួរមួយទៅជួរមួយមានចំងាយ ៦ម៉ែត្រ និងពីគុម្ពមួយទៅគុម្ពមួយមានចំងាយបីម៉ែត្រ (៦ម × ៣ម) ដូច្នេះដង់ស៊ីតេដើមកៅស៊ូក្នុងមួយហិកតាគឺមានចំនួន ៥៥៥ដើម នៅក្នុងទិសដៅពីលិច-កើត និងជើង-ត្បូង។

### ៣-៥-៦-៩ ការបោះបង្គោល ការខួងរណ្តៅដាំកៅស៊ូ ការប្រើប្រាស់ជី និងការថែទាំ

**៥៣.** ត្រូវបោះបង្គោលប្រវែង១,២០ម ដោយឫស្សី ឫកូនឈើ ដើម្បីដៅសញ្ញាចំណាំចំណុចត្រូវដាំ។ ចុងម្ខាងនៃបង្គោលត្រូវសំរូចដើម្បីងាយស្រួលបោះ។ ត្រូវប្រើផ្លែខួងសម្រាប់ខួងរណ្តៅដែលមានមុខកាត់ចន្លោះពី ៦០-៧០ស.ម នឹងមានជម្រៅពី ៦៥-៨០ស.ម។ ត្រូវដាក់ជីធម្មជាតិទ្រាប់បាតចំនួន២តោន ក្នុងមួយហិកតា និងជីគីមី NPK ចំនួន ៥០០គ.ក្រក្នុងមួយហិកតា ដើម្បីរក្សាសុខភាព និងជម្រុញដល់ការលូតលាស់របស់កូនកៅស៊ូដែលទើបនឹងដាំថ្មីៗ។ ក្នុងរយៈពេល ០៥ឆ្នាំ ដំបូងនៃការដាំដុះក្រុមហ៊ុននឹងប្រើប្រាស់ជីសរីរាង្គ (Organic Fertilizer) ប្រភេទ (COMIX) ចំនួន ១តោន ក្នុងមួយហិកតា ដើម្បីជួយបំប៉នដល់ការលូតលាស់នៃកូនកៅស៊ូដែលបានដាំ។

**៥៤.** ត្រូវជ្រើសរើសកូនបំបៅដែលមានសុខភាពល្អដូចៗគ្នា (បើអាចធ្វើទៅបាន) សម្រាប់ដាំនៅក្នុងឡូត៍ចំការ។ ពេលដាំត្រូវកាត់កបាតថង់ចេញហើយដាក់ថង់ក្នុងរណ្តៅ បន្ទាប់មកយកថង់ចេញតាមបណ្តោយផ្ទៃរថង់ តែធ្វើយ៉ាងណាកុំមានការទង្គិចដល់ឫសរយាង និងជៀសវាងការបែកដុំដីកំណើត (ដីដែលនៅក្នុងថង់) ដែលបង្កអោយមានមានការប៉ះពាល់ធ្ងន់ធ្ងរដល់កន្ទ្បោមឫស។

Draft

**៥៥.** ត្រូវថែទាំកូនកៅស៊ូដែលទើបនឹងដាំហើយ តាមរយៈការត្រួតពិនិត្យជាទៀងរាល់សប្តាហ៍ ក្រោយពេលដាំរួច។ ត្រូវកាត់ (ប្រលេះ) ចេញនូវរាល់ខ្នែងទាំងអស់ដែលពកចេញថ្មី លើកលែងតែពន្លកខ្នែងណា ដែលដុះចេញពីភ្នែកបំប៉ោតែមួយប៉ុណ្ណោះ។ ១០%នៃចំនួនកូនកៅស៊ូសរុប ដែលបានដាំក្នុងថង់បណ្តុះកូនកៅស៊ូ ត្រូវរក្សាទុកសំរាប់ជួសកូនដែលអន់ និងងាប់។

**៥៦.** ទំនៀមទំលាប់នៅក្នុងប្រទេសយើង ម្ចាស់ចំការតែងតែធ្វើការដាំដំណាំរួមផ្សំមួយចំនួនដូចជា: ដំឡូងមី (ការអនុវត្តន៍ នៅខេត្តកំពង់ចាម និងតំបន់មួយចំនួនក្នុងខេត្តកំពង់ធំ ខេត្តក្រចេះ និងខេត្តស្ទឹងត្រែង) ល្ង សណ្តែកដី សណ្តែកសៀង និងសណ្តែកបាយ ដើម្បីកាត់បន្ថយតម្លៃគ្រប់គ្រងនិងថែទាំ និងការកែលំអគុណភាពដី។ តែម្ចាស់ចំការមួយចំនួន (ជាពិសេសជនជាតិបរទេស - ចំការកៅស៊ូក្រុមហ៊ុន Socfin-KCD នៅប៊ូស្រា ចំការកៅស៊ូក្រុមហ៊ុន ហេងអភិវឌ្ឍន៍ នៅស្រុកអណ្តូងមាស ខេត្តរតនៈគីរី...។ល។ គេមិនដាំដំណាំរួមផ្សំទេ តែគេដាំ (សាប) ពពួករុក្ខជាតិគ្របដី (រុក្ខជាតិគម្រប) ជាប្រភេទស្មៅវល្លិស្ថិតក្នុងអំបូរសណ្តែកដើម្បីធ្វើជាគម្របដី។ រុក្ខជាតិប្រភេទនេះមានលទ្ធភាពចាប់យកអាសូតពី បរិយាកាស និងការទ្រទ្រង់ដល់លក្ខណៈជីវសាស្ត្ររបស់ពពួកបាក់តេរីដែលមានអាសូត (Nitrogen Contained Bacteria) ដែលអាចរក្សា និងកែលំអគុណភាពដីបាន។

## ៣-៥-៧ ផែនការបែងចែក និងការរៀបចំដីដាំដុះប្រចាំឆ្នាំ

Draft

**៥៧.** ផែនការបែងចែកផ្ទៃដីដាំដុះ និងការរៀនចំដីសំរាប់គំរោងវិនិយោគដាំដើមកៅស៊ូ របស់ក្រុមហ៊ុន ត្រូវបានគ្រោងអនុវត្តទុកសំរាប់ការដាំដុះក្នុងរយះពេល ០៤ឆ្នាំ (២០០៨-២០១១) ដែលក្នុងនោះអត្រាបែងចែកផ្ទៃដីដាំដុះជាភាគរយ របស់ចំការកៅស៊ូ គ្រោងដាំដុះលើផ្ទៃដីប្រមាណ ៩៣% ស្មើនឹងផ្ទៃដីចំនួន ៧.៥៥០ ហិកតា និងក្រុមហ៊ុនយើងខ្ញុំ ក៏បានត្រៀមផ្ទៃដីប្រហែល ៥៥០ ហិកតាទៀត (៧%) សំរាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនានា ដែលរួមមាន: ប្រព័ន្ធផ្លូវគមនាគមន៍ក្នុងតំបន់ដីសម្បទាន ការសាងសង់ប្រព័ន្ធស្រោចស្រពសំណង់អគារការដ្ឋាន រោងចក្រកែច្នៃ និង សំណង់ផ្សេងៗទៀត ។

**ផែនការបែងចែកផ្ទៃដីដាំដុះតាមបណ្តាលឆ្នាំ ២០០៨ ដល់ ២០១១ និង ការប៉ាន់ស្មានផ្ទៃដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធ:**

| No. | មុខដំណាំ Crops | ២០០៨ | ២០០៩ | ២០១០ | ២០១១ | Total (ha) | % |
|---|---|---|---|---|---|---|---|
| 1- | ផ្ទៃដីដាំកៅស៊ូ Rubber | Year-1 | Year-2 | Year-3 | Year-4 | | |
| | | 880 | 1,370 | 2,450 | 2,850 | **7,550** | **93** |
| 2- | ផ្ទៃដីប៉ាន់ស្មានសំរាប់ហេដ្ឋារចនាសម្ព័ន្ធ | 120 | 130 | 150 | 150 | **550** | **7** |
| | ប្រព័ន្ធផ្លូវ (៥៦ខ្សែ) | | | | | **237** | |

| | | | | | | |
|---|---|---|---|---|---|---|
| រោងចក្រកែច្នៃកៅស៊ូចំនួន ០១ (សាងសង់ក្រៅតំបន់ដីសម្បទាន) | | | | | | |
| ស្នាក់ការធំនិងផ្ទះស្នាំនៅរបស់ថ្នាក់ដឹកនាំ | | | | | 25 | |
| ស្នាក់ការរង និងផ្ទះកម្មករ | | | | | 20 | |
| ប្រព័ន្ធស្រោចស្រប-ឃ្លាំង-រោងជាង ប៉ុស្តិ៍យាម-ប៉មយាមភ្លើង និង សំណង់ផ្សេងៗទៀត | | | | | 268 | |
| **សរុបផ្ទៃដី Total Area(Ha)** | **1,000** | **1,500** | **2,600** | **3,000** | **8,100** | **100** |




Draft

**៥៨.** ផ្ទៃដីដែលក្រុមហ៊ុនអាចដាំដុះបាន ក្រោយពីកាត់ចេញផ្ទៃដីសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ មានត្រឹមតែ ៧.៩៥០ ហិកតា លើផ្ទៃដីសម្បទានរួមសរុប ៨.១០០ ហិកតា។



**៥៩.** ក្រុមហ៊ុនគ្រោងចាប់ផ្តើមដំណើរការដាំដុះកៅស៊ូនៅឆ្នាំ២០០៨ និងគ្រោងដាំអោយអស់ចប់សព្វគ្រប់នៅឆ្នាំ ២០១១ លើផ្ទៃដីសម្បទានចំនួន ៨.១០០ ហិកតានេះ ។ (លំអិតក្នុងឧបសម្ព័ន្ធ-១)

**៦០.** នៅក្នុងផ្ទៃដីសរុបចំនួន ៨.១០០ ហិកតានេះ ក្រុមហ៊ុនបានគ្រោងធ្វើការដាំដុះកៅស៊ូចំនួន ៧.៥៥០ ហិកតា និងបែងចែកផ្ទៃដីដាំដុះ តាមឆ្នាំនិមួយៗដូចខាងក្រោម :

នៅឆ្នាំទី១ (២០០៨): ក្រុមហ៊ុនគ្រោងដាំដុះកៅស៊ូ ចំនួន ៨៨០ ហិកតា ក្នុងតំបន់ទី-១ ។
នៅឆ្នាំទី២ (២០០៩): ក្រុមហ៊ុនគ្រោងដាំដុះកៅស៊ូបន្ថែមចំនួន ១.៣៧០ ហិកតា ក្នុងតំបន់ទី-២
នៅឆ្នាំទី៣ (២០១០): ក្រុមហ៊ុនគ្រោងដាំដុះកៅស៊ូបន្ថែមចំនួន ២.៤៥០ ហិកតា ក្នុងតំបន់ទី-៣
នៅឆ្នាំទី៤ (២០១១): ក្រុមហ៊ុនគ្រោងដាំដុះកៅស៊ូបន្ថែមចំនួន ២.៨៥០ ហិកតា ក្នុងតំបន់ទី-៤

**តារាងបង្ហាញពីផែនការដាំដុះដើមកៅស៊ូរយៈពេល ០៤ឆ្នាំ (២០០៨-២០១១) ដូចខាងក្រោម:**
**ផែនការរៀបចំដីវិនិយោគដាំដំណាំកៅស៊ូ ពីឆ្នាំទី១ ដល់ឆ្នាំទី ៤**

**ឯកតា: ហិកតា**

| មុខដំរីដំណាំ | 2008 | 2009 | 2010 | 2011 |
|---|---|---|---|---|
| ដំណាំកៅស៊ូ | 880 | 1,370 | 2.450 | 2,850 |
| **សរុបផ្ទៃដាំដុះ (ហ.ត)** | **880** | **1,370** | **2.450** | **2,850** |

<u>បញ្ជាក់</u> : ផ្ទៃដីដែលអាចដាំដុះបានមានចំនួន ៧.៥៥០ ហិកតា ។




Draft

## ៣-៥-៨ ការធ្វើផែនការវិនិយោគលើផលិតកម្ម និងអាជីវកម្ម

### ៣-៥-៨-១ ការគណនាថ្លៃដើមផលិតក្នុង ០១ហិកតា

**៦១.** ការចំណាយថ្លៃដើមផលិតកម្មលើការដាំដុះដំបូងក្នុងមួយហិកតា ត្រូវបានគ្រោងចំនួន**៨៥១.៥៣ ដុល្លាអាមេរិក** សំរាប់ដាំដំណាំកៅស៊ូដែលក្នុងនោះរួមបញ្ចូលចំណាយអថេរមួយចំនួនដូចខាងក្រោម :

**តំលៃជាឯកតាដុល្លាក្នុង ១ហ.ត**

| ល.រ | មុខចំណាយ | កៅស៊ូ |
|---|---|---|
| ១- | ឈូសឆាយ-រៀបចំដី | ៣០០.០០ |
| ២- | ចំណាយពូជ ជី ថ្នាំ ឧបករណ៍ដាំ | ៣៩៩.០០ |
| ៣- | ចំណាយពលកម្ម ដាំ ថែទាំ ដាក់ជីបំប៉ | ១៣១.៦៣ |
| ៤- | ចំណាយគ្រប់គ្រង ផ្សេងៗ | ២០.០០ |
| | **ចំណាយសរុប(ដុល្លាអាមេរិក)** | **៨៥១.៥៣** |

### ៣-៥-៨-២ ផែនការចំណាយផលិតកម្មដាំដុះ និងកែច្នៃ

**៦២.** គំរោងចំណាយនៃការអភិវឌ្ឍន៍ដាំដុះដំណាំកសិ-ឧស្សាហកម្ម កៅស៊ូ និងការកែច្នៃផលិតផលរបស់ក្រុមហ៊ុន ត្រូវបានបែងចែកជាបីប្រភេទគឺ :

១- ចំណាយលើការដាំដុះដំបូង

២- ចំណាយប្រតិបត្តិការអាជីវកម្ម

៣- ចំណាយអថេរ

**៦៣.** ចំណាយលើការដាំដុះដំបូង-ចំណាយប្រតិបត្តិការអាជីវកម្មត្រូវបានគិតជាចំណាយអថេរ ( Variable Costs ) ដែលក្នុង នោះមាន :

- ចំណាយលើពលកម្ម ការដាំដុះ ការថែទាំជាប្រចាំ
- ចំណាយលើការប្រមូលផល ចំណាយលើការកែច្នៃផលិតផល
- ចំណាយលើការដឹកជញ្ជូន ចំណាយលើ Marketing និង
- ចំណាយប្រតិបត្តិការផ្សេងៗទៀត ។

**៦៤.** ចំណាយអថេរ ( Fixed Costs ) គឺរួមបញ្ចូលលើប្រាក់រំលោះរបស់អាគារ ឃ្លាំង ទព្វសំភារៈចំណាយលើការប្រាក់ ធានារ៉ាប់រងសង្គម និងចំណាយលើការបង់ពន្ធប៉ាតង់នានា ។ នៅឆ្នាំទី១ ថវិកាគ្រោងចំណាយសរុបមានចំនួន **២.៦៤៧.៦៩០ ដុល្លាអាមេរិក** សំរាប់ចំណាយលើការដាំដុះ កៅស៊ូនៅលើផ្ទៃដីមានចំនួន ៨៨០ ហិកតា ដែលក្នុងនោះមាន ការចំណាយលើការដាំដុះមានចំនួន ៧៤៩.៣៤៦ ដុល្លាអាមេរិក ចំណាយប្រតិបត្តិ



Draft

ការណ៍សរុបមានចំនួន ៧៨៣.០០០ ដុល្លាអាមេរិក ចំណាយថេរមានចំនួន ១.១៦៦.៣៨៤ ដុល្លាអាមេរិក។ ចំណាយលំអិត មានបង្ហាញជូនក្នុង ឧបសម្ព័ន្ធ៣-២ តារាងឧបសម្ព័ន្ធ-៥ក ។

**៦៥.** នៅឆ្នាំទី២ ផ្ទៃដីដាំដុះកៅស៊ូចំនួន ១.៣៧០ ហិកតា នឹងត្រូវធ្វើការអភិវឌ្ឍន៏ ដែលត្រូវការចំណាយថវិកាចំនួន ៣.៥៣០.៥១៦ ដុល្លាអាមេរិក ក្នុងនោះការចំណាយលើការដាំដុះមានចំនួន ១.១៦៦.៥៩៦ ដុល្លាអាមេរិក ចំណាយប្រតិបត្តិការមានចំនួន ១.២២៧.១០០ ដុល្លាអាមេរិក និង ចំណាយថេរមានចំនួន ១.១៣៦.៨២០ ដុល្លាអាមេរិក ។

**៦៦.** នៅឆ្នាំទី៣ ផ្ទៃដីដាំដុះគ្រោងដាំកៅស៊ូមានចំនួន ២.៤៥០ ហិកតា ដែលការចំណាយសរុបមានចំនួន ៥.២០៤.៦២៨ ដុល្លាអាមេរិក ក្នុងនោះការចំណាយលើការដាំដុះមានចំនួន ២.០៨៦.២៤៨ ដុល្លាអាមេរិក ចំណាយប្រតិបត្តិការមានចំនួន ១.៩៦៥.៦០០ ដុល្លាអាមេរិក និងចំណាយថេរមានចំនួន១.១៥២.៧៨០ ដុល្លាអាមេរិក ។

**៦៧.** នៅឆ្នាំទី៤ ផ្ទៃដីដាំដុះកៅស៊ូគ្រោងចំនួន ២.៨៥០ ហិកតា ដែលការចំនាយមាន ៦.៤១៩.៨១៦ ដុល្លាអាមេរិក ក្នុងនោះការចំណាយលើការដាំដុះមានចំនួន ២.៤២៦.៨៦០ ហិកតា ដែលការចំណាយប្រតិបត្តិការមានចំនួន ២.៨១៨.៩០០ ដុល្លាអាមេរិក និងការចំណាយថេរមានចំនួន ១.១៧៤.០៥៦ ដុល្លាអាមេរិក ។

**៦៨.** សមាមាត្រនៃការចំណាយឆ្នាំទី១ លើការដាំដុះដំបូងមានចំនួន ២៨ ភាគរយ នៃចំណាយសរុប ២៩ភាគរយ លើចំណាយប្រតិបត្តិការ និង ៤៣ ភាគរយ លើចំណាយថេរ ។

**៦៩.** ការចំណាយលើការដាំដុះ និងការធ្វើអាជីវកម្ម ដំណាំកសិ-ឧស្សាហកម្ម ដើមកៅស៊ូរយះពេល ០៤ឆ្នាំដំបូងត្រូវបានប៉ាន់ស្មាន និងរៀបរាប់លំអិតដូចខាងក្រោមនេះ :

**តារាង ៣-៤ : ការចំណារលើការដាំដុះដំបូង ដំណាំកសិ-ឧស្សាហកម្ម (កៅស៊ូ) ពីឆ្នាំទី១ដល់ឆ្នាំទី៤**

| N0 | មុខចំណាយ | ឆ្នាំទី-១ 2008 | ឆ្នាំទី-២ 2009 | ឆ្នាំទី-៣ 2010 | ឆ្នាំទី-៤ 2011 |
|---|---|---|---|---|---|
| A- | **ចំណាយអរថេរ** Varible Costs: | | | | |
| | ចំណាយសរុបការដាំដុះ Plantation Development | 749,346 | 1,166,596 | 2.086.248 | 2,426,860 |
| | សរុបចំណាយប្រតិបត្តិការ Operting Costs | 783,000 | 1,227,100 | 1,965,600 | 2,818,900 |
| B- | **ចំណាយអរថេរ** Fixed Costs: | | | | |
| | សរុបចំណាយថេរ Total Fixed Costs: | 1,115,344 | 1,136.820 | 1,152,780 | 1,174.056 |
| C- | **សរុបចំណាយរួម Total** Costs: (US$) | **2,647.690** | **3,530.516** | **5,204,628** | **6,419.816** |

### ៣-៥-៩ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ

### ៣-៥-៩-១ ប្រព័ន្ធផ្លូវ

**៧០.** គំរោងផែនការសំរាប់ការរៀបចំប្រព័ន្ធផ្លូវក្នុងតំបន់ដីសម្បទាន ក្រុមហ៊ុនមានគំរោងផែនការសាងសង់ផ្លូវដោយមិនគិតពីផ្លូវចាស់។ ដោយឡែកក្នុងតំបន់ផ្ទៃដីដែលរក្សាទុកដូចជា តំបន់ទ្រនាប់ តំបន់ដកតាមដីកា និង តំបន់បំរុងទុក គឺក្រុមហ៊ុនយើងខ្ញុំមិនសាងសង់ផ្លូវកាត់ទេ ។ ក្នុងករណីចាំបាច់ ឬមានកិច្ចសហការពីប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន ក្រុមហ៊ុននឹងសាងសង់ផ្លូវចាស់ដែលមានស្រាប់ដើម្បីប្រើប្រាស់រួមជាសាធារណៈ។

**៧១.** ដើម្បីឱ្យការធ្វើអាជីវកម្ម-ផលិតកម្ម ក្នុងតំបន់ដីសម្បទានដំណើរការ ទទួលបានជោគជ័យក្រុមហ៊ុនមានផែនការសាងសង់ប្រព័ន្ធផ្លូវ ០៥ប្រភេទ សំរាប់ជាខ្សែខ័ណ្ឌព្រំប្រទល់ជុំវិញតំបន់ដីសម្បទាន ជាព្រំប្រទល់សំរាប់បែងចែកអនុតំបន់ដីសម្បទាន និងការបែងចែកឡូត៍ សំរាប់ការដាំដុះ និងការគ្រប់គ្រង។ ប្រព័ន្ធផ្លូវទាំង ០៥ប្រភេទមាន :

១- ផ្លូវមេព័ន្ធតំបន់ដីសម្បទាន ចំនួន ១ខ្សែ ដែលមានទទងេ ៦ ម៉ែត្រ

២- ផ្លូវមេក្នុងតំបន់ដីសម្បទាន ចំនួន ៤ ខ្សែ ដែលមានទទឹង ១២ ម៉ែត្រ

៣- ផ្លូវមេបែងចែកអនុតំបន់ ចំនួន ៣ ខ្សែ ដែលសាងសង់ពីលិចទៅកើតដែលមានទទឹង ៨ម៉ែត្រ

៤- ផ្លូវមេក្នុងអនុតំបន់ដីសម្បទានសរុបមានចំនួន ៣០ ខ្សែ សាងសង់ពីទិសខាងជើងទៅទិសខាងត្បូងចំនួន ១៥ ខ្សែ ស្មើនឹង ៦៥ គីឡូម៉ែត្រ និង ពីទិសខាងលិចទៅទិសខាងកើតមានចំនួន ១៥ ខ្សែ ស្មើនឹង ៦១ គីឡូម៉ែត្រ ។ ប្រវែងទទឹងសាងសង់ពីលិចទៅកើតមានទទឹង ៤ ម៉ែត្រ និងសាងសង់ពីជើងទៅត្បូងមានទទឹង ៦ ម៉ែត្រ

៥- ផ្លូវឡូតិ៍មានចំនួន ៣០ខ្សែ សាងសង់ពីទិសខាងជើងទៅទិសខាងត្បូងចំនួន ១៥ ខ្សែ ស្មើនឹង ៧៧ គីឡូម៉ែត្រ និងពីទិសខាងលិចទៅទិសខាងកើត ចំនួន ១៥ខ្សែ ស្មើនឹង ៧៤ គីឡូម៉ែត្រ ប្រវែងទទឹងសាងសង់ពីលិចទៅកើតមានទទឹង ៤ ម៉ែត្រនិងពីជើងទៅត្បូងមានទទឹង ៦ម៉ែត្រ។

**៧២.** ផ្លូវទាំង០៥ប្រភេទនេះមានបញ្ជាក់ក្នុងតារាងខាងក្រោម បន្ទាប់ពីមានការអត្ថាធិប្បាយពីផ្លូវនីមួយៗ។ ប្រភេទផ្លូវនីមួយៗមានទំហំ ប្រវែងខុសៗគ្នា និងមានអត្ថប្រយោជន៍ សំរាប់បំរើឱ្យការធ្វើអាជីវកម្ម-ផលិតកម្មផ្សេងៗពីគ្នាទៅតាមប្រភេទផ្លូវ។ តាមការសិក្សារបស់ក្រុមហ៊ុន និងការរៀបចំគំនូសប្លង់(ផែនទីជូនភ្ជាប់) សំរាប់ការសាងសង់ប្រព័ន្ធផ្លូវទាំងនោះ ដូចខាងក្រោម :

Draft

៧៣. **ផ្លូវមេព័ទ្ធជុំវិញតំបន់ដីគំរោងវិនិយោគ** : ផ្លូវមេព័ទ្ធជុំវិញតំបន់ដីសម្បទាន គឺជាផ្លូវដែលត្រូវសាងសង់ព័ទ្ធជុំវិញតំបនដីសម្បទាន ដែលមានប្រវែងសរុប ៦២ គីឡូម៉ែត្រ និងទទឹងផ្លូវមានប្រវែង ៦ ម៉ែត្រ សរុបផ្ទៃដីសំរាប់កសាងផ្លូវព័ទ្ធតំបន់ដីសម្បទានមានចំនួន ៣៧,២ ហិកតា ។

៧៤. ផ្លូវនេះត្រូវសាងសង់ចាប់ផ្តើមពីចំណុច A រត់ទៅទិសខាងជើងត្រង់តាមព្រំប្រទល់ដីសម្បទានឆ្លងកាត់ចំណុច $A_{15}$ ចំណុច $R_1$ ចំណុច $A_{16}$ ដល់ចំណុច B ។ ពីចំណុច B រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងកើតត្រង់ឆ្លងកាត់ចំណុច $A_{11}$ ដល់ចំណុច C ។ ពីចំណុច C រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងជើងត្រង់ដល់ចំណុច D ។ ពីចំណុច D រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងកើតត្រង់ឆ្លងកាត់ចំណុច $A_6$ ចំណុច $A_7$ ចំណុចនិង $A_2$ ដល់ចំណុច E ។ ពីចំណុច E រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងជើងត្រង់ចំងាយឆ្លងកាត់ ចំណុច $C_5$ ចំណុច $C_2$ ដល់ចំណុច F ។ ពីចំណុច F រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងជើងឈាងខាងកើត ឆ្លងកាត់ចំណុច $R_4$ ដល់ចំណុច G ។ ពីចំណុច G រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងកើតត្រង់ឆ្លងកាត់ចំណុច $A_1$ ដល់ចំណុច H ។ ពីចំណុច H រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងត្បូងត្រង់ ឆ្លងកាត់ចំណុច $B_{20}$ ចំណុច $C_1$ និង ចំណុច $B_7$ ដល់ចំណុច I ។ ពីចំណុច I រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងកើតត្រង់ដល់ចំណុច J ។ ពីចំណុច J រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងត្បូងត្រង់ ឆ្លងកាត់ចំណុច $R_3$ ចំណុច $B_{17}$ និងចំណុច $R_8$ ដល់ចំណុច K ។ ពីចំណុច K រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងត្បូងឈាងខាងលិចដល់ចំណុច L ។ ពីចំណុច L រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងជើងឈាងខាងលិច ឆ្លងកាត់ចំណុច $B_{15}$ ចំណុច $R_6$ និង ចំណុច $B_{13}$ ដល់ចំណុច M ។ ពីចំណុច M រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងជើងត្រង់ឆ្លងកាត់ចំណុច $B_{18}$ និងចំណុច $B_{19}$ ដល់ចំណុច N ។ ពីចំណុច N រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងលិចឆ្លងកាត់ចំណុច $B_{10}$ ចំណុច $B_{11}$ និង ចំណុច $B_2$ ដល់ចំណុច O ។ ពីចំណុច O រត់តាមព្រំប្រទល់ដីសម្បទានទៅទិសខាងត្បូង រួចបន្តរត់ទៅទិសខាងកើត ដោយឆ្លងកាត់ចំណុច $A_{17}$ ចំណុច $A_{18}$ ចំណុច $A_{19}$ ចំណុច $A_{13}$ និងចំណុច $A_{14}$ រួចបន្តរត់ទៅទិសខាងកើតឈាងខាងត្បូងដល់ចំណុច A ដែលជាចំណុចដើមវិញ ។ ចំណុចនិយាមកាតាមចំណុចនីមួយៗ ខាងលើ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣-៤ ជូនភ្ជាប់ ។

៧៥. សារៈប្រយោជន៍របស់ផ្លូវនេះ គឺដើម្បីជារបងកំណត់ព្រំប្រទល់ដីសម្បទាន ជាផ្លូវសំរាប់ធ្វើចរាចរក្នុងការធ្វើអាជីវកម្ម-ផលិតកម្ម ការដឹកជញ្ជូនជាផ្លូវយុទ្ធសាស្រ្តសំរាប់ការពារសន្តិសុខ និងសុវត្ថិភាពដូចជាៈការពារភ្លើងឆេះព្រៃ និងចល័តកំលាំងសន្តិសុខនៅពេលមានបញ្ហា..... ។ល ។

៧៦. **ប្រភេទផ្លូវមេក្នុងតំបន់ដីសម្បទាន** : គំរោងផែនការក្នុងការរៀបចំកសាងផ្លូវមេក្នុងតំបន់ដីសម្បទានគឺមានចំនួន ០៤ខ្សែ សាងសង់ពីទិសខាងជើងទៅទិសខាងត្បូង ចំនួន ២ ខ្សែ និង ពីទិសខាងលិចទៅទិសកើតចំនួន ២ខ្សែ ។ ផ្ទៃដីសាងសង់ប្រវែងប៉ាន់ស្មានសរុបចំនួន ៣៥ម៉ែត្រ និងមានទទឹង ១២ម៉ែត្រ សរុបផ្ទៃដីសំរាប់កសាងផ្លូវមេក្នុងតំបន់ដីសម្បទានមាន ចំនួន ៤២ ហិកត ។ ផ្លូវនេះគ្រោងសាងសង់ដូចតទៅ :



Draft

- **ខ្សែទី១** ចាប់ផ្ដើមពីចំណុច $R_4$ រត់ទៅទិសខាងជើងត្រង់ ឆ្លងកាត់ចំណុច $B_{12}$ ចំណុច $B_6$ និង ចំណុច $R_{12}$ ដល់ចំណុច $R_{11}$ ដែលជាចំណុចបញ្ចប់នៃផ្លូវខ្សែទី១នេះ ។
- **ខ្សែទី២** ចាប់ផ្ដើមចំណុច $R_5$ រត់ទៅទិសខាងជើងត្រង់ ឆ្លងកាត់ចំណុច $B_{18}$ និង ចំណុច $R_7$ ដល់ចំណុច $R_6$ ដែលជាចំណុចបញ្ចប់នៃផ្លូវខ្សែទី ២ នេះ ។
- **ខ្សែទី៣** សាងសង់ពីលិចទៅកើតត្រង់កើតដោយ ចាប់ផ្ដើមពីចំណុច $R_1$ រត់ទៅទិសខាងកើតត្រង់ដល់ចំណុច $R_9$ រួចបន្តរត់ទៅទិសខាងជើងត្រង់ដល់ចំណុច $R_{10}$ ពីចំណុច $R_{10}$ រត់ទៅទិសខាងកើតត្រង់ដល់ចំណុច $R_{11}$ ពីចំណុច $R_{11}$ ដែលជាចំណុចបញ្ចប់នៃផ្លូវខ្សែទី៣ នេះ ។
- **ខ្សែទី៤** សាងសង់ពីលិចទៅកើតដោយចាប់ផ្ដើមពីចំណុច $R_2$ រត់ទៅទិសខាងកើតត្រង់ឆ្លងកាត់ ចំណុច $R_2$ ដល់ចំណុច $R_5$ ដែលជាចំណុចបញ្ចប់នៃផ្លូវខ្សែទី៤ នេះ ។
- **ខ្សែទី៥** សាងសង់ពីលិចទៅកើតដោយ ចាប់ផ្ដើមពីចំណុច $R_7$ រត់ទៅតិសខាងកើតត្រង់ដល់ចំណុច $R_8$ ដែលជាចំណុចបញ្ចប់នៃផ្លូវ ខ្សែទី៥ នេះ ។ ចំណុចនិយាមកាតាមចំណុចនីមួយៗ ខាងលើ មានភ្ជាប់ក្នុងឧបសម្ព័ន្ធ ៣-៤ ជូនភ្ជាប់ ។

**៧៧.** សារៈប្រយោជន៍របស់ផ្លូវមេក្នុងតំបន់ដីសម្បទានគឺ: (១) ជាផ្លូវសំរាប់ធ្វើចរាចរគ្រឿងចក្រដឹកនាំផលិតផលដែលទទួលបានពីការដាំដុះ និងផលិតផលផ្សេងៗ សំរាប់បំរើអោយការធ្វើអាជីវកម្ម-ផលិតកម្ម (២) ជាផ្លូវយុទ្ធសាស្ត្រសំរាប់ការពារសន្តិសុខ និងសុវត្ថិភាពដូចជា ការពារភ្លើងឆេះព្រៃ និងចល័តកំលាំងនៅពេលមានឧប្បទ្ទវហេតុដែលអាចកើតមានឡើង ក្នុងតំបន់ដីសម្បទានជាយថាហេតុ...។ល។ និង (៣) ចរាចរត្រួតពិនិត្យក្នុងតំបន់ដីសម្បទាន។

**៧៨.** **ប្រភេទផ្លូវមេចែកអនុតំបន់ :** ផ្លូវមេចែកអនុតំបន់ គឺជាប្រភេទផ្លូវកសាងឡើងដើម្បីកំណត់អនុតំបន់ទាំង ០៤ សំរាប់ធ្វើការដាំដុះតាមឆ្នាំនីមួយៗ និងសំរាប់បំរើឱ្យការធ្វើអាជីវកម្ម-ផលិតកម្ម។ ផ្លូវនេះក្រុមហ៊ុនមានផែនការកសាងចំនួន ០៣ខ្សែ ប្រវែងប៉ាន់ស្មានសរុបចំនួន ១១គីឡូម៉ែត្រ និងទទឹងផ្លូវ ៤ម៉ែត្រ ផ្ទៃដីប៉ាន់ស្មាន សំរាប់ការសាងសង់ សរុបមានចំនួន ៤.៤ ហិកតា។ ផ្លូវ ០៣ ខ្សែ នេះក្រុមហ៊ុនមានផែនការកសាងដូចតទៅ :

- **ផ្លូវខ្សែទី ១** ផ្លូវនេះមានគំរោងសាងសង់ ចាប់ផ្ដើមពីចំណុច $G_4$ រត់ទៅទិសខាង កើតត្រង់ដល់ចំណុច $C_3$ ដែលជាចំណុចបញ្ចប់របស់ផ្លូវនេះ ។
- **ផ្លូវខ្សែទី ២** ផ្លូវនេះមានគំរោងសាងសង់ ចាប់ផ្ដើមពីចំណុច $A_4$ រត់ទៅទិសខាង កើតត្រង់ដល់ចំណុច $A_3$ ដែលជាចំណុចបញ្ចប់របស់ផ្លូវនេះ ។

Draft

- **ផ្លូវខ្សែទី ៣** ផ្លូវនេះមានគំរោងសាងសង់ ចាប់ផ្តើមពីចំណុច $B_{16}$ រត់ទៅទិសខាង កើតត្រង់ដល់ចំណុច $B_{17}$ ដែលជាចំណុចបញ្ចប់របស់ផ្លូវនេះ ។ ឧបសម្ព័ន្ធ ៣-៤ ជូនភ្ជាប់

៧៩. សារៈប្រយោជន៍របស់ផ្លូវមេ ក្នុងអនុតំបន់ដីសម្បទានគឺ :

- ❖ ជាផ្លូវសំរាប់កំណត់ព្រំប្រទល់ឡូត៍ក្នុងអនុតំបន់នីមួយៗ ។
- ❖ ជាផ្លូវសំរាប់អ្នកបច្ចេកទេសងាយស្រួលក្នុងការត្រួតពិនិត្យ និងគ្រប់គ្រង ។
- ❖ ជាផ្លូវសំរាប់កម្មករប្រមូលផលតាមឡូត៍នីមួយៗ ។
- ❖ ជាផ្លូវសំរាប់ធ្វើចរាចរគ្រឿងចក្រ ដឹកនាំផលដែលទទួលបានពីការដាំដុះ និង ផលិតផលផ្សេងៗ សំរាប់បំរើអោយការធ្វើអាជីវកម្ម-ផលិតកម្ម ។
- ❖ ជាផ្លូវយុទ្ធសាស្ត្រ សំរាប់ការពារសន្តិសុខ និងសុវត្ថិភាពដូចជា ការពារភ្លើងឆេះព្រៃ និងចល័តកំលាំងនៅពេលមានឧប្បទ្ទវហេតុកើតមានឡើងក្នុងតំបន់ដីសម្បទាន..... ។ល ។
- ❖ ចរាចរត្រួតពិនិត្យក្នុងតំបន់ដីសម្បទាន និងការពារការហូរច្រោះដី.... ។ល ។

៨០. **ប្រភេទផ្លូវមេក្នុងអនុតំបន់:** ផ្លូវមេក្នុងអនុតំបន់ដីសម្បទានគ្រោងធ្វើការសាងសង់មានចំនួន ៣០ ខ្សែ ប្រវែងផ្លូវប៉ាន់ស្មាន សំរាប់កាសាងសង់នេះប្រមាណ ១២៦ គីឡូម៉ែត្រ ។ ផ្លូវនេះមានផែនការសាងសង់ដោយមានទទឹងខុសគ្នាគឺ :

- ផ្លូវដែលសាសង់ពីទិសខាងជើង ទៅតិសខាងលិចមានប្រវែង ៦៥ គីឡូម៉ែត្រ និង ទទឹង ប្រវែង ៦ ម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសរុបចំនួន ៣៩ ហិកតា ។
- ផ្លូវដែលសាងសង់ពីតិសខាងកើត ទៅទិសខាងលិចមានប្រវែង ៦៥ គីឡូម៉ែត្រ និងមានទទឹងផ្លូវប្រវែង ៤ម៉ែត្រ និង មានផ្ទៃដី ប៉ាន់ស្មាន់សរុបចំនួន ២៤.៤ ហិកតា ។

ផ្លូវមេក្នុងងនុតំបន់ដីសម្បទាន មានគំលាតពីផ្លូវមួយទៅផ្លូវមួយចំងាយ ១គីឡូម៉ែត្រ (ផែនទីជូនភ្ជាប់) ។

៨១. សារៈប្រយោជន៍ របស់ ផ្លូវមេក្នុងអនុតំបន់ដីសម្បទានគឺ:

- ❖ ជាផ្លូវសំរាប់កំណត់ព្រំប្រទល់ឡូត៍ក្នុងអនុតំបន់នីមួយៗ ។
- ❖ ជាផ្លូវសំរាប់អ្នកបច្ចេកទេសងាយស្រួលក្នុងការត្រួតពិនិត្យ និងគ្រប់គ្រង ។
- ❖ ជាផ្លូវសំរាប់កម្មករប្រមូលផលតាមឡូត៍នីមួយៗ ។
- ❖ ជាផ្លូវសំរាប់ធ្វើចរាចរគ្រឿងចក្រ ការដឹកនាំផលដែលទទួលបានពីការដាំដុះ និងផលិតផលផ្សេងៗ សំរាប់បំរើអោយការធ្វើអាជីវកម្ម-ផលិតកម្ម ។

Draft

- ❖ ជាផ្លូវយុទ្ធសាស្ត្រសំរាប់ការពារសន្តិសុខ និង សុវត្ថិភាពដូចជា ការពារភ្លើងឆេះព្រៃ និង ចល័តកំលាំងនៅពេលមានឧប្បទ្វហេតុកើតមានឡើង ក្នុងតំបន់ដីសម្បទាន... ។ល។
- ❖ ចរាចរត្រួតពិនិត្យក្នុងតំបន់ដីសម្បទាន និង ការពារការហូរច្រោះដី... ។ល។

៨២. **ផ្លូវឡូតិ៍ :** ផ្លូវឡូតិ៍គ្រោងធើ្វការសាងសង់សរុបចំនួន ៣០ ខ្សែ មានប្រវែង ១៥១ គីឡូម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសំរាប់សាងសង់មានចំនួន ៩០ ហិកតា។ ផ្លូវនេះសាងសង់ពីលិចទៅកើតចំនួន ១៥ ខ្សែ មានប្រវែង ៧៧ គីឡូម៉ែត្រ និងមានទទឹង ៤ ម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសំរាប់សាងសង់ចំនួន ៣០.៨ ហិកតា ។ សាងសង់ពីជើងទៅត្បូងចំនួន ១៥ ខ្សែ មានប្រវែង ៧៤ គីឡូម៉ែត្រ និងមានទទឹង ៦ម៉ែត្រ ផ្ទៃដីប៉ាន់ស្មាន សំរាប់សាងសង់ចំនួន ៥៩.២ ហិកតា។ ផ្លូវឡូតិ៍គ្រោង ធ្វើការសាងសង់គំលាតពីផ្លូវមួយទៅផ្លូវមួយចំងាយ ៥០០ ម៉ែត្រ ឬគំលាត ៥០០ ម៉ែត្រ ពីផ្លូវផ្សេងៗទៀត។

៨៣. សារៈប្រយោជន៍របស់ផ្លូវឡូតិ៍ក្នុងតំបន់ដីសម្បទានគឺ :

- ❖ ជាផ្លូវសំរាប់កំណត់ព្រំប្រទល់ឡូតិ៍ក្នុងអនុតំបន់នីមួយៗ។
- ❖ ជាផ្លូវសំរាប់អ្នកបច្ចេកទេសងាយស្រួលក្នុងការត្រួតពិនិត្យ និងគ្រប់គ្រង។
- ❖ ជាផ្លូវសំរាប់កម្មករប្រមូលផលតាមឡូតិ៍នីមួយៗ។
- ❖ ជាផ្លូវសំរាប់ធ្វើចរាចរគ្រឿងចក្រ ការដឹកនាំផលដែលទទួលបានពីការដាំដុះ និងផលិតផលផ្សេងៗសំរាប់បំរើអោយការធ្វើអាជីវកម្ម -ផលិតកម្ម។
- ❖ ជាផ្លូវយុទ្ធសាស្ត្រ សំរាប់ការពារសន្តិសុខ និងសុវត្ថិភាពដូចជា ការពារភ្លើងឆេះព្រៃ និងចល័តកំលាំងនៅពេលមានឧប្បទ្វហេតុកើតមានឡើងក្នុងតំបន់ដីសម្បទាន... ។ល។
- ❖ ជាផ្លូវសំរាប់អោយកម្មករងាយស្រួលក្នុងការជញ្ជូនផលិតផលដោយកំលាំងពលកម្មការថែទាំការពារភ្លើង និងសំរាប់ប្រមូលផ្តុំផលរួចដឹកចេញមកកន្លែងប្រមូលផ្តុំផលតាមឡូតិ៍ និងបន្តមកកាន់រោងចក្រ ។
- ❖ ចរាចរត្រួតពិនិត្យក្នុងតំបន់ដីសម្បទាន និង ការពារហូរច្រោះដី..... ។ល។

<u>**បញ្ជាក់:**</u> *គំរោងការសាងសង់ផ្លូវទាំង ៥ ប្រភេទខាងលើ នៅពេលអនុវត្ត ក្រុមហ៊ុននឹងដំណើរការតាមសណ្ឋានដីជាក់ស្តែង។ គំរោងផែនការសំរាប់ការរៀបចំប្រព័ន្ធផ្លូវក្នុងតំបន់ដីសម្បទាន ក្រុមហ៊ុនមានផែនការសាងសង់ប្រព័ន្ធផ្លូវដោយមិនគិតពីផ្លូវចាស់។ ដោយឡែកក្នុងតំបន់ដីរក្សាទុកក្រុមហ៊ុនមិនសាងសង់ផ្លូវកាត់ទេ។ ចំពោះផ្លូវចាស់ដែលមានស្រាប់ក្នុងករណីចាំបាច់ និងមានកិច្ចសហការល្អ ពីប្រជាពលរដ្ឋ អាជ្ញាធរមូលដ្ឋាន ក្រុមហ៊ុននឹងធ្វើការសាងសង់ ឬជួសជុលផ្លូវចាស់ដែលមានស្រាប់នោះ សំរាប់ប្រើប្រាស់រួមជាសាធារណៈ។*

Draft

**តារាង ៣-៨: តារាងសង្ខេបអំពីប្រព័ន្ធផ្លូវសំរាប់ដំណើរការអភិវឌ្ឍន៍ក្នុងតំបន់ដីសម្បទាន**

| ល.រ | ប្រភេទផ្លូវ | ចំនួនខ្សែ | ប្រវែង គ.ម | ទទឹងផ្លូវ ម៉ែត្រ | ផ្ទៃដី ហ.ត |
|---|---|---|---|---|---|
| ១ | ផ្លូវមេព័ទ្ធជុំវិញដីសម្បទាន | ១ | ៦២ | ៦ | ៣៧.២ |
| ២ | ផ្លូវមេនៅក្នុងដីសម្បទាន | ៥ | ៣៥ | ១២ | ៤២ |
| ៣ | ផ្លូវមេបែងចែកអនុតំបន់ដីសម្បទាន | ៣ | ១១ | ៤ | ៤.៤ |
| ៤ | ផ្លូវមេក្នុងអនុតំបន់ដីសម្បទានពីលិចទៅកើត | ១៥ | ៦១ | ៤ | ២៤.៤ |
| | ផ្លូវមេក្នុងអនុតំបន់ដីសម្បទានពីជើងទៅត្បូង | ១៥ | ៦៥ | ៦ | ៣៩ |
| ៥ | ផ្លូវបែងចែកឡូត៍ពីលិចទៅកើត | ១៥ | ៧៧ | ៤ | ៣០.៨ |
| | ផ្លូវបែងចែកឡូត៍ពីជើងទៅត្បូង | ១៥ | ៧៤ | ៦ | ៥៩.២ |
| | សរុប | | ៣៨៥ | | ២៣៧ |

### ៣-៥-៩-២ ប្រព័ន្ធស្រោចស្រព

**៨៤.** ប្រភពសំរាប់បំរើអោយការស្រោចស្រពក្នុងតំបន់ដីសម្បទាន មានលក្ខណៈអំណោយផលល្អ នៅផ្នែកត្បូងនៃតំបន់ដីសម្បទាន ជាពិសេសកាន់តែប្រសើរថែមទៀត នៅផ្នែកខាងត្បូងឈាងខាងកើត ព្រោះស្ទឹងជីនិតហូរកាត់ក្បែរ ដោយឡែកផ្នែកខាងជើងនិងខាងលិចនៃតំបន់ដីសម្បទាន ក៏មានប្រភពទឹកបានមកពី អូរព្រៃក ធម្មជាតិមួយចំនួនទៀតដូចជា អូរបឹងសំរោង អូរកំបោរ និង អូរកំបោររលួស ។ ប្រភពទឹកទាំងនេះយើងអាចទាញ យក មកស្រោចស្រពនៅក្នុងអនុតំបន់មួយចំនួនដូចជា : អនុតំបន់ទី **I** និង ផ្នែកខាងលិចនៃអនុតំបន់ទី **II.a** អាចប្រើប្រាស់ទឹកមកពីអូរកំបោរ និង អូរកំបោររលួស អនុតំបន់ទី **II.a II.b II.c III.b** អាចប្រើប្រាស់ទឹកបានពី អូរបឹងសំរោង ដោយឡែកតំបន់ទី **IV** អាចទាញទឹកពីស្ទឹងជីនិតយកមកប្រើប្រាស់បានដែរ។ វិធីសាស្រ្តទាញទឹកយកមកប្រើប្រាស់គឺ ក្រុមហ៊ុនមានផែនការស្ថាបនាប្រព័ន្ធប្រឡាយកសាងប្រឡាយបណ្តែត និងប្រើប្រាស់ទុយោសំរាប់ការស្រោចស្រព ទៅតាមស្ថានភាពដីជាក់ស្តែងក្នុងតំបន់ដីសម្បទាន។ ម៉្យាងវិញទៀតក្នុងករណីជួបការលំបាក លើការទាញទឹកពីប្រភពទឹកដែលបានរៀបរាប់ខាងលើក្រុមហ៊ុនក៏មានផែនការ កសាងប្រព័ន្ធធារាសាស្រ្ត ស្តាក់ទឹកភ្លៀង និងប្រើប្រាស់ប្រព័ន្ធទឹកក្រោមផងដែរ ។

### ៣-៥-៩-៣ រោងចក្រកែច្នៃផលិតផល

**៨៥.** ក្រុមហ៊ុនមានគំរោងសាងសង់រោងចក្រកែច្នៃផលិតផល ០១កន្លែង ដោយគ្រោងផ្ទៃដីប្រហែល ២៥ហិកតាសំរាប់ការសាងសង់។ រោងចក្រកែច្នៃនេះ គ្រោងចំណាយថវិកានៃទុនវិនិយោគប្រហែល ៧.៨០០.០០០ ដុល្លាអាមេរិក។ ទីតាំងសំណង់រោងចក្រកែច្នៃ ក្រុមហ៊ុននឹងសហការជំនាញជាមួយមូលដ្ឋាន និងអាជ្ញាធរដែនសិក្សា



Draft

រកទីតាំងក្រៅតំបន់ដីសម្បទានណា ដែលមានលក្ខណៈអំណោយផល និងស្របស្របបំផុតសំរាប់ការសាងសង់។ លំអិតការចំណាយនៃការសាងសង់រោង ចក្រនឹងបង្ហាញជូនក្នុងចំណុច **៣-៥-៩-៥**។

### ៣-៥-៩-៤ ទីតាំង ទំហំផ្ទៃដីសំរាប់ហេដ្ឋារចនាសម្ព័ន្ធ

**៨៦.** ក្រុមហ៊ុនមានផែនការសាងសង់សំណង់មួយចំនួន សំរាប់ដំណើរក្នុងការធ្វើអាជីវកម្ម-ផលិតកម្មក្នុងតំបន់ដីសម្បទាន ដែលសំណង់ទាំងនោះមានដូចតទៅ :

- ផ្លូវមេព័ទ្ធជុំវិញតំបន់ដីសម្បទាន គឺជាផ្លូវដែលត្រូវសាងសង់ពទ្ធ័ជុំវិញតំបន់ដីសម្បទាន ដែលមានប្រវែង ៦២ គីឡូម៉ែត្រ និងទទឹងផ្លូវប្រវែង ៦ ម៉ែត្រ សរុបផ្ទៃដីសំរាប់កសាងផ្លូវមេពន្ធ័តំបន់ដីសម្បទាន មានចំនួន ៣៧,២ ហិកតា។
- ផ្លូវមេនៅក្នុងដីសម្បទានចំនួន ០៤ ខ្សែ សាងសង់ពីទិសខាងជើងទៅទិសខាងត្បូង ០២ ខ្សែ និងពីទិសខាងលិចទៅទិសខាងកើត ចំនួន ០២ ខ្សែ។ ផ្ទៃដីសាងសង់ប្រវែងប៉ាន់ស្មាន សរុបចំនួន ៣៥ គីឡូម៉ែត្រ និងមានទទឹង ១២ ម៉ែត្រ សរុបផ្ទៃដីសំរាបកសាងផ្លូវមេក្នុងតំបន់ដីសម្បទានចំនួន ៤២ ហិកតា។
- ផ្លូវមេចែកអនុតំបន់ចំនួនមានចំនួន ០៣ខ្សែ ប្រវែងប៉ាន់ស្មានសរុប ១១ គីឡូម៉ែត្រ និងទទឹងផ្លូវ ០៤ម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសំរាប់ការសាងសង់សរុបមានចំនួន ៤.៤ ហិកតា។
- ផ្លូវមេអនុតំបន់ដីសម្បទានមានចំនួន ៣០ខ្សែ ប្រវែងផ្លូវប៉ាន់ស្មានសំរាប់ធ្វើការសាងសង់នេះប្រមាណ ១២៦ គីឡូម៉ែត្រ និង ទទឹងប្រវែង ៦ម៉ែត្រ ផ្ទៃដី ប៉ាន់ស្មានសំរាប់សាងសង់មាន ចំនួន ៦៣.៤ ហិកតា។ ផ្លូវនេះមានការសាងសង់ដោយមានទទឹង ខុសគ្នាគឺ : ១- ផ្លូវដែលសាងសង់ ពីទិសខាងជើងទៅទិសខាងត្បូងមានប្រវែង ៦៥ គីឡូម៉ែត្រ និងមានទទឹង ប្រវែង ៦ ម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសរុបមានចំនួន ៣៩ ហិកតា និង ២ ផ្លូវដែលសាងសង់ពីទិសខាងកើត ទៅទិសខាងលិចមានប្រវែង ៦៥ គីឡូម៉ែត្រ និងមានទទឹង ផ្លូវប្រវែង ៤ម៉ែត្រ និងមានផ្ទៃដីប៉ាន់ស្មានសរុបចំនួន ២៤.៤ ហិកតា។
- ផ្លូវឡូតិ៍គ្រោងធើវការសាងសង់សរុបចំនួន ៣០ខ្សែ មានប្រវែង ១៥១ គីឡូម៉ែត្រ ផ្ទៃដីប៉ាន់ស្មានសំរាប់សាងសង់មានចំនួន ៩០ហិកតា ។ ផ្លូវនេះសាងសង់ពីលិចទៅកើតចំនួន ១៥ ខ្សែ មានប្រវែង ៧៧ គីឡូម៉ែត្រ និង មានទទឹង ៤ម៉ែត្រ ផ្ទៃដីប៉ាន់ស្មាន សំរាប់សាងសង់ មានចំនួន ៥៩.២ ហិកតា ។

**សរុបផ្ទៃដីប៉ាន់ស្មានសំរាប់ប្រពន្ធ័ផ្លូវទាំង ៥ ប្រភេទ ខាងលើមានចំនួន ២៣៧ ហិកតា។**

- រោងចក្រកែច្នៃចំនួន ១ ផ្ទៃដីប៉ាន់ស្មានសរុបចំនួន ២៥ ហិកតា។ ទីតាំងសំណង់រោងចក្រ កែច្នៃ ក្រុមហ៊ុននឹងសហការជាមួយជំនាញមូលដ្ឋាន និងអាជ្ញាធរដែនសិក្សារកទីតាំងក្រៅតំបន់ដីសម្បទាន ដែលមានលក្ខណៈអំណោយផល និងសមស្របបំផុតសំរាប់ការសាងសង់ ។

Draft

- ទីស្នាក់ការធំ និងផ្ទះស្នាក់នៅរបស់ថ្នាក់ដឹកនាំក្រុមហ៊ុនមានចំនួន ០១ ស្ថិតនៅក្នុងអនុតំបន់ទី Ia ផ្ទៃដីប៉ាន់ស្មានសរុបចំនួន ២៥ ហិកតា។
- ទីស្នាក់ការរង និង ជំរុំកម្មករមានចំនួន ៤កន្លែង ដែលទីស្នាក់ការរង និង ជំរុំកម្មករ ស្ថិតនៅរាយតាមអនុតំបន់នីមួយៗ ផ្ទៃដីប៉ាន់ស្មានសរុបចំនួន ២០ ហិកតា ។
- ប៉ុស្តិ៍យាមចំនួន ៤ ស្ថិតនៅអនុតំបន់ទី I.a អនុតំបន់ទី II.c អនុតំបន់ទី III.a អនុតំបន់ទី IV
- ប៉មយាមភ្លើងឆេះព្រៃ និងសន្តិសុខចំនួន ៤១ ស្ថិតនៅរាយក្នុងតំបន់ដីសម្បទានដូចមានផែនទីជូនភ្ជាប់។
- ផ្ទៃដីគ្រោងសំណង់ផ្សេង ដែលមានចែងក្នុងប្រការ ៧ នៃចំនុច ៧.៥ និង ប្រការ ៨ចំនុច ៨.២ សរុបចំនួន ៨៨ ហិកតា ។

**៨៧.** សំណង់ដែលរៀបរាប់ខាងលើបញ្ជាក់ទីតាំងកាន់តែច្បាស់នៅក្នុងផែនទីដីសម្បទាន និងតារាងចំណុចនិយាមកា (តារាងអាប់ស៊ីស និងអរដោនេ) មានបង្ហាញជូននៅក្នុងតារាងខាងក្រោម :

**តារាង ៣-៩ : តារាងបញ្ជាក់ចំនួន ប្រភេទ ទីតាំង និងផ្ទៃដីសំណង់**

| ល.រ | ប្រភេទសំណង់ | ចំនួនសរុប | ផ្ទៃដី (ហ.ត) | ចំនុចទីតាំងសំណង់ |
|---|---|---|---|---|
| ១ | ប្រព័ន្ធផ្លូវ | ៥៦ខ្សែ | ២៣៧ | ផែនទីជូនភ្ជាប់ |
| ២ | រោងចក្រកែច្នៃកៅស៊ូ | ០១ | | សាងសង់ក្រៅតំបន់ដីសម្បទាន |
| ៣ | ស្នាក់ការធំនិងផ្ទះស្នាក់នៅ | ០១ | ២៥ | X: ៥៤៩៣៤៦ និង Y: ១៣៩១៨៤៧ |
| | របស់ថ្នាក់ដឹកនាំក្រុមហ៊ុន | | | |
| ៤ | ស្នាក់ការង និង ផ្ទះកម្មករ | ០៤ | ២០ | X: ៥៥៤១៥២ និង Y: ១៣៧៨៦១២<br>X: ៥៥៤១២១ និង Y: ១៣៨៣១៧១<br>X: ៥៤៣២៤៤ និង Y: ១៣៨៣៨២៥<br>X: ៥៤៨៦៨២ និង Y: ១៣៩០៤៨៦ |
| ៥ | ប៉ុស្តិ៍យាម | ០៤ | | X: ៥៤៨៦៤៩ និង Y: ១៣៩១៦៩០<br>X: ៥៤២១៤១ និង Y: ១៣៨៣៨៤៦<br>X: ៥៥៦៩៨៥ និង Y: ១៣៨៤១៣៨<br>X: ៥៥៤១៦៦ និង Y: ១៣៧៧១៨៥ |
| ៦ | ប៉មយាមភ្លើងឆេះព្រៃ | ៤១ | | ចំនុនិយាមាករមានក្នុងឧបសម្ព័ន្ធជូនភ្ជាប់ |
| ៧ | ផ្ទៃដីគ្រោងសំរាប់សំណង់ផ្សេងៗ ដែលមានចែងក្នុងប្រការ ៧ នៃ | | ២៦៨ | |

| | | | | |
|---|---|---|---|---|
| | ចំណុច ៧.៥ និងប្រការ៨ ចំណុច ៨.២ | | | |
| | **សរុបផ្ទៃដីសំរាប់សំណង់ហេដ្ឋារចនាសម្ព័ន្ធ** | | **៩៥០** | |

## ៣-៥-៩-៥ ការចំណាយលើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ

**៨៨.** ការចំណាយលើការសាងសង់ត្រូវបានគណនាសំរាប់អនុវត្តពីឆ្នាំទី១ ដល់ឆ្នាំទី៧ (២០០៨-២០១៧) មានដូចខាងក្រោម:

- ការចំណាយលើការសាងសង់សំណង់ស៊ីវិល ត្រូវបានប៉ាន់ស្មានថានឹងចំណាយរយៈពេល១០ឆ្នាំដំបូង (២០០៨-២០១៧) ដោយគ្រោងថវិកាប្រមាណ ១.៥១២.០០០ ដុល្លាអាមេរិក។ ថវិកាគ្រោងចំណាយលើសំណង់ស៊ីវិលនេះនឹងត្រូវប្រើប្រាស់ប្រហែល ២៩៤.០០០ ដុល្លាអាមេរិក នៅឆ្នាំទី១ ទឹកប្រាក់ប្រមាណ ២០២.០០០ ដុល្លាអាមេរិក នៅឆ្នាំទី២ ទឹកប្រាក់ចំនួន ១៦០.០០០ ដុល្លាអាមេរិកនៅឆ្នាំទី៣ ទឹកប្រាក់ចំនួន ២១៤.០០០ ដុល្លាអាមេរិក នៅឆ្នាំទី៤ ទឹកប្រាក់ប្រមាណ ១៩០.០០០ ដុល្លាអាមេរិក នៅឆ្នាំទី ៥ និងទឹកប្រាក់ប្រមាណ ១១០.០០០ ដុល្លាអាមេរិក ក្នុងមួយឆ្នាំទី៦ ១០៤.០០០ ដុល្លាអាមេរិក នៅឆ្នាំទី៧ ១១០.០០០ ដុល្លាអាមេរិក នៅឆ្នាំទី៨ ៦៤.០០០ ដុល្លាអាមេរិក នៅឆ្នាំទី៩ និង ៦៤.០០០ ដុល្លាអាមេរិកនៅឆ្នាំទី ១០។ (តារាងលំហូរសាច់ប្រាក់ )
- ថវិកាចំនួន ៧.៨០០.០០០ ដុល្លាអាមេរិក គ្រោងចំណាយសំរាប់ការតំលើងរោងចក្រកែច្នៃចំនួន ០១ កន្លែង ។

**តារាង ៣-១០: តារាងចំណាយសាងសង់សំណង់ស៊ីវិលតាមឆ្នាំ ពីឆ្នាំទី-១ ដល់ឆ្នាំទី-១០**

| បណ្តាឆ្នាំ | ចំណាយសាងសង់សំណង់ស៊ីវិល (USD) | ចំណាយសាងសង់រោងចក្រ (USD) |
|---|---|---|
| ឆ្នាំទី១ (២០០៨) | 294,000.00 | |
| ឆ្នាំទី២ (២០០៩) | 202,000.00 | |
| ឆ្នាំទី៣ (២០១០) | 160,000.00 | |
| ឆ្នាំទី៤ (២០១១) | 214,000.00 | 300,000.00 |
| ឆ្នាំទី៥ (២០១២) | 190,000.00 | 1,000,000.00 |
| ឆ្នាំទី៦ (២០១៣) | 110,000.00 | 2,800,000.00 |
| ឆ្នាំទី៧ (២០១៤) | 104,000.00 | 3,000,500.00 |
| ឆ្នាំទី៨ (២០១៥) | 110,000.00 | 700,000.00 |
| ឆ្នាំទី៩ (២០១៦) | 64,000.00 | |

Draft

| | | |
|---|---|---|
| ឆ្នាំទី១០ (២០១៧) | 64,000.00 | |
| **សរុបចំណាយ(US$)** | **1512,000.00** | **7,800,000.00** |

## ៣-៥-៩-៦ មធ្យោបាយ និងទព្វសំភារៈ-ឧបករណ៍សំរាប់ដំណើរការ

**៨៩. គ្រឿងចក្រ និងសំភារះបរិក្ខារផលិតកម្មៈ** ដើម្បីបំរើការងារវិនិយោគនេះ ក្រុមហ៊ុនត្រូវការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនខ្នាតតូច និងធំ គ្រឿងចក្រ ឧបករណ៍ និងសំភារៈបរិក្ខារ ដែលបំរើឱ្យការងារដាំដុះ ដោយក្រុមហ៊ុនគ្រោងនឹងចំណាយទឹកប្រាក់សរុបចំនួន ១.០២០.០០០ ដុល្លាអាមេរិក ក្នុងនោះរួមមាន :

- ការដឹកជញ្ជូនមានរថយន្តធំ ១០ គ្រឿង រថយន្តដឹកជញ្ជូនធុនមធ្យម ចំនួន ១០ គ្រឿង Pick-Up Double Cab ចំនួន ៣ គ្រឿង ។
- ការងារឈូសឆាយត្រាក់ទ័រចំនួន ១០ គ្រឿង អស្ការវ៉ាទ័រចំនួន ២ គ្រឿង និងប៊ូដូស័រចំនួន ៣គ្រឿង សំរាប់ការងារឈូសឆាយ ត្រាក់ទ័រកៀរ រុញដីចំនួន ១គ្រឿង ។
- ម៉ាស៊ីនភ្លើង ០៣គ្រឿង និងម៉ាស៊ីនបូមទឹក ១០គ្រឿង ។
- ដើម្បីកែច្នៃផលិតផល ក្រុមហ៊ុននឹងសាងសង់រោងចក្រកែច្នៃ ១កន្លែង ដែលសរុបជាទឹកប្រាក់ចំនួនប្រមាណជា ៧.៨០០.០០០ ដុល្លាអាមេរិក ។ សរុបចំណាយលើគ្រឿងចក្រ និងការសាងសង់រោងចក្រចំនួន ៨.៨២០.០០០ ដុល្លាអាមេរិក ។ (ឧបសម្ព័ន្ធ ៣-២ តារាងឧបសម្ព័ន្ធ ៦-១) ។

**៩០.** ផែនការទិញគ្រឿងចក្រ ត្រូវបានគ្រោងសំរាប់រយៈពេល ០៩ ឆ្នាំ គឺទឹកប្រាក់ចំនួន ៤៧០.០០០ ដុល្លាអាមេរិក ត្រូវចំណាយនូវឆ្នាំទី៣ ៤៨.០០០ ដុល្លាអាមេរិក ត្រូវចំណាយនូវឆ្នាំទី៤ ៤០.០០០ ដុល្លាអាមេរិក ត្រូវចំណាយនៅឆ្នាំទី៥ ២០.០០០ ដុល្លាអាមេរិក ត្រូវចំណាយនៅឆ្នាំទី៦ ៣០.០០០ ដុល្លាអាមេរិក ត្រូវចំណាយនៅឆ្នាំទី៧ ៥២.០០០ ដុល្លាអាមេរិក ត្រូវចំណាយនៅឆ្នាំទី៨ និងនៅឆ្នាំទី៩ ២០.០០០ ដុល្លាអាមេរិក ។ សេចក្ដីលំអិតនៃ ការចំណាយនេះ ត្រូវបានបង្ហាញក្នុងឧបសម្ព័ន្ធ ៣-២ តារាងឧបសម្ព័ន្ធ ៦-២,៣ ផែនការមេ ។

**តារាង ៣-១១: តារាងគ្រឿងចក្រ-គ្រឿងម៉ាស៊ីន និងសំភារៈបរិក្ខារ**

| No | មុខចំណាយ (Item) | ឯកតា (Unit) | បរិមាណ Qty | តំលៃឯកតា (US$) | សរុប Total Costs(US$) |
|---|---|---|---|---|---|
| A- | គ្រឿងចក្រ Heavy Equipment : | LS | | | **1,020,000.00** |
| B- | Factory & Processing Plants : | | | | |
| 1 | រោងចក្រកែច្នៃផលិតផល | Unit | 1 | 7,800,000.00 | 7,800,000.00 |
| | សរុបតំលៃរោងចក្រ-B | | | | **7,800,000.00** |
| C | **សរុបចំណាយ** Total Costs(US$) | | | | **8,820,000.00** |

Draft

៩១. **ទព្វសំភារៈ-គ្រឿងចក្រសង្ហារឹមការិយាល័យ :** ក្នុងកិច្ចដំណើរការទាំងការងារគ្រប់គ្រងរដ្ឋបាល និង ការងារបច្ចេកទេសក្នុងផលិតកម្មអាជីវកម្ម-រោងចក្រកែច្នៃ ក្រុមហ៊ុននឹងត្រូវការទិញទព្វសំភារៈការិយាល័យ និង គ្រឿងសង្ហារឹមមួយចំនួន ដែលមានតំលៃសរុបចំនួន ២៧.៨៣០ ដុល្លាអាមេរិក ដែលមានដូចជាៈ ម៉ាស៊ីន កុំព្យូទ័រ ម៉ាស៊ីនព្រីនធ័រ ម៉ាស៊ីន Scanner, ម៉ាស៊ីន Fax, ទូរស័ព្ទ ម៉ាស៊ីន Photocopies, និងសំភារៈ ការិយាល័យផ្សេងៗទៀតដូចជា : តុ កៅអី ទូដាក់ឯកសារ ...។ល។ ដើម្បីបំរើដល់កិច្ចការគ្រប់គ្រងគំរោងការ វិនិយោគនេះ។ សេចក្តីលំអិតនៃការចំណាយនេះត្រូវបានបង្ហាញក្នុងឧបសម្ពន្ធ័ ៣-២ តារាងឧបសម្ពន្ធ័៦-៣ ផែនការមេ។

**តារាង ៣-១២ : តារាងទព្វសំភារៈ-គ្រឿងសង្ហារឹមការិយាល័យ**

| ល.រ | **មុខចំណាយ** (Item) | **សរុប Total Costs (ដុល្លា)** |
|---|---|---|
| **A -** | ទព្វសំភារៈការិយាល័យ | ២១.៣៥០,០០ |
| **B -** | គ្រឿងសង្ហារឹមការិយាល័យ | ៦.៤៨០,០០ |
| **C -** | **សរុបចំណាយ Total** Costs(US$) | **២៧.៨៣០,០០** |

## ៣-៥-១០ កំលាំងពលកម្ម

៩២. **ពលកម្មក្នុងស្រុក:** ក្នុងគំរោងអនុវត្តការងារវិនិយោគនេះ ក្រុមហ៊ុននឹងប្រើប្រាស់កំលាំងពលកម្មដែល មានក្នុងប្រទេស សំដៅចូលរួមចំណែកកាត់បន្ថយភាពគ្មានការងារធ្វើរបស់បុគ្គលិក និងអ្នកបច្ចេកទេសកម្ពុជា ដែលបានបណ្តុះបណ្តាលរួចពីគ្រឹះស្ថានបច្ចេកទេសនានា។ អ្នកស្រុកដែលរស់នៅក្បែរតំបន់ដីសម្បទាន ក្រុមហ៊ុន ត្រូវបានផ្តល់អត្ថិភាពឱ្យចូលធ្វើការងារមុនគេទៅតាមសមត្ថភាពរបស់ខ្លួន។

៩៣. *បុគ្គលិក-កម្មករ អ្នកបច្ចេកទេស និងអ្នកគ្រប់គ្រងប្រមាណ ៩៨៤នាក់ នឹងត្រូវបានប្រើប្រាស់នៅ ឆ្នាំទី-១ និងកើនរហូតដល់ ១.០១១ នាក់ នៅឆ្នាំទី៥ នៃការអនុវត្តន៏គំរោងនេះ។ ពីឆ្នាំទី-៦ដល់ឆ្នាំទី-១០ ក្រុមហ៊ុនគ្រោងនឹងប្រើប្រាស់កំលាំងពលកម្មចំនួនជាង ១.០១៦នាក់ សំរាប់ការធ្វើផលិតកម្មនិងអាជីវកម្មនេះ។*

៩៤. ថវិកាដែលត្រូវចំណាយសំរាប់ពលកម្មក្នុងស្រុក ក្រុមហ៊ុនគ្រោងនឹងចំណាយប្រហែល ៥០៥.៨០០ ដុល្លា អាមេរិក នៅឆ្នាំទី-១ នឹងកើនដល់ ៥៧៥.៥០០ ដុល្លាអាមេរិក នៅឆ្នាំទី-៥ នឹងទឹកប្រាក់ប្រមាណជា ៨៧៦.០០០ ដុល្លាអាមេរិក ក្នុងមួយឆ្នាំ នៅឆ្នាំទី៦-១០។ វិស្វករ និងអ្នកបច្ចេកទេស នឹងអាចទទួលប្រាក់ខែ ៤០០-៦០០ ដុល្លាអាមេរិក ក្នុងមួយខែ អ្នកចាត់ចែងការ-គ្រប់គ្រងគំរោងវិនិយោគនេះ នឹងអាចទទួល ប្រាក់ខែបានចំនួន ៤៥០-៨០០ ដុល្លាអាមេរិក ក្នុងមួយខែ និងចំពោះអ្នកគ្រប់គ្រងរដ្ឋបាល នឹងទទួលបាន ២០០-៣៥០ ដុល្លាអាមេរិក ក្នុងមួយខែ។ កម្មករជំនាញធ្វើការជាអចិន្ត្រៃយ៍ ដែលមានចំនួន ៣៥០នាក់

គ្រោងនឹងទទួលបានប្រាក់ខែចំនួន ៧០-១២០ ដុល្លាអាមេរិកក្នុងមួយខែ និងជាកម្មករគ្មានជំនាញដែលជាកម្មករអណ្តែត ក្រុមហ៊ុននឹងជួលមកធ្វើការតាមរដូវកាលមានប្រមាណ ៦០០-៧០០នាក់ គឺអាចទទួលបាន ៤០-៩០ ដុល្លាអាមេរិកក្នុង១ ខែ ។

**៩៥.** ទឹកប្រាក់ធានារ៉ាប់រងសង្គម ត្រូវបានគិតប្រមាណជា ០៧ ភាគរយ នៃទឹកប្រាក់ចំណាយពលកម្មសរុប ។ នៅឆ្នាំទី១ ថវិកាប្រហែល ៣៥.៤០៦ ដុល្លាអាមេរិក នឹងត្រូវចំណាយលើផ្នែកនេះនឹងកើនរហូតពីមួយឆ្នាំទៅមួយឆ្នាំ គឺប្រមាណ ៤០.២៧៨ ដុល្លាអាមេរិក នៅឆ្នាំទី៥ និង ៦១.៣២០ ដុល្លាអាមេរិក នៅឆ្នាំទី១០ ។ សេចក្តីលំអិតនៃគំរោងប្រើប្រាស់ពលកម្មក្នុងស្រុកមានរៀបរាប់បង្ហាញជូនក្នុងឧបសម្ព័ន្ធ ៣-២ តារាងឧបសម្ពន្ធ័ ៧ក-គ ។

| បរិយាយ | ឆ្នាំទី-១ | ឆ្នាំទី-២ | ឆ្នាំទី-៣ | ឆ្នាំទី-៤ | ឆ្នាំទី-៥ | ឆ្នាំទី-៦ | ឆ្នាំទី-៧ | ឆ្នាំទី-៨ | ឆ្នាំទី-៩ | ឆ្នាំទី-១០ |
|---|---|---|---|---|---|---|---|---|---|---|
| ចំនួនពលកម្ម | 986 | 1032 | 1062 | 1118 | 1011 | 1016 | 1018 | 1018 | 1018 | 1016 |
| ចំណាយពលកម្ម | 517,800 | 564,600 | 592,600 | 619,400 | 575,400 | 876,000 | 895,200 | 895,200 | 895,200 | 876,000 |

សំគាល់ : ចំនួនពលកម្មគិតជាអ្នក និង ចំណាយគិតជា ដុល្លាអាមេរិក ។




**៩៦. ពលកម្មបរទេស :** ការងារបច្ចេកទេសក្នុងការធ្វើវិនិយោគលើការអភិវឌ្ឍន៍ផ្នែកកសិ-ឧស្សាហកម្មនេះ ក្រុមហ៊ុនទាមទានូវជំនាញច្បាស់លាស់ក្នុងការអនុវត្តន៍។ ក្រុមហ៊ុនយល់ឃើញថា ថ្វីត្បិតតែយើងមានវិស្វករអ្នកបច្ចេកទ្បេក្នុងស្រុកមួយចំនួន រួចហើយក្តី ក៏ប៉ុន្តែកិច្ចការបរទេសនេះ ចាំបាច់ត្រូវការកំលាំងបន្ថែមពីខាងក្រៅ ដើម្បីធានាថាការងារទាំងអស់ ត្រូវបានធ្វើត្រឹមត្រូវ តាមបទដ្ឋានបច្ចេកទេស ដែលជាវិស្វករជំនាញមកពីប្រទេស វៀតណាម ចំនួន ០២រូប ឱ្យមកជួយណែនាំការងារជ្រើសពូជ ការងារដាំដុះ និងថែទាំដំណាំកៅស៊ូរបស់ក្រុមហ៊ុន។ ថ្លៃឈ្នួលពលកម្មបរទេស គឺប្រមាណពី ៥០០-១.០០០ ដុល្លាអាមេរិក ក្នុងមួយខែ សំរាប់បំ

Draft

វីការក្នុងគំរោងវិនិយោគនេះ។ ថវិការដែលត្រូវចំណាយសំរាប់ពលកម្មបរទេស គឺវែគាងចំណាយប្រហែល ១២.០០០ ដុល្លាអាមេរិក ក្នុងមួយឆ្នាំ ពីឆ្នាំទី-១ ដល់ឆ្នាំទី៤ (ក្រុមហ៊ុនជួលតែវិស្វករវៀតណាមរយៈពេល ៤ឆ្នាំដំបូង )។ នៅឆ្នាំទី៧ ដល់ឆ្នាំទី៩ ក្រុមហ៊ុនជួលវិស្វករវៀតណាមដើម្បីជួយកែច្នៃកៅស៊ូ។ គំរោងប្រើប្រាស់ពលកម្ម និងជំនាញការបរទេស មានបង្ហាញក្នុងឧបសម្ពន្ធ ៣-២ តារាងឧបសម្ពន្ធ ៧ក.ខ.គ។ ខាង ក្រោមនេះ ដ្យាក្រាមបង្ហាញពីការចំណាយក្នុងការប្រើប្រាស់កំលាំងពលកម្ម។




## ៣-៥-១១ ការងារគ្រប់គ្រង-បណ្តុះបណ្តាល

**៩៧.** បុគ្គលិក-កម្មករកម្ពុជា ដែលត្រូវបានទទួលការជ្រើសរើសពីក្រុមហ៊ុនរួចហើយ ក្រុមហ៊ុនមានគំរោងយកទៅបណ្តុះបណ្តាលការងារជំនាញបច្ចេកទេសបន្ថែម ក្នុងរយៈពេលពី ០១-០៣ខែ ឬលើសពីនេះ អាស្រ័យលើការចាំបាច់។ ម្យ៉ាងវិញទៀត បុគ្គលិក-កម្មករ អាចមានឱកាសសិក្សារៀនសូត្រដោយផ្ទាល់នៅឯការដ្ឋានដាំដុះ ជាមួយនឹងអ្នកជំនាញបច្ចេកទេស ដោយការអនុវត្តន៍ផ្ទាល់។

## ៣-៥-១២ រចនាសម្ព័ន្ធនៃការគ្រប់គ្រងគំរោងវិនិយោគ

**៩៨.** ក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ (TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.)** មានទីស្នាក់ការខ្លួនស្ថិតនៅ ផ្លូវជាតិលេខ៦ ភូមិគំដីជាន់ខ្លា ឃុំដីវិជាន់ខ្លា ស្រុកស្ទឹកសែន ខេត្តកំពង់ធំ នៃព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទទំនាក់ទំនងលេខ (៨៥៥) ២៣ ៣៥៥ ៤២២ ទូរសារលេខ ( ៨៥៥) ២៣ ២២២ ៩៧៥ ដែលតំណាងដោយលោក DUONG QUOC VIET ជនជាតិវៀតណាម ឋានៈប្រធានក្រុមព្រឹក្សាភិបាលក្រុមហ៊ុនមានគណនីលេខ ០១០០.២៥០.០១៣.៨៧៧ នៅធានាគារអភិវឌ្ឍនៈ។

៩៩. គំរោងបង្កើតកសិដ្ឋានដាំដុះដំណាំកសិកម្ម-ឧស្សាហកម្មៈ កៅស៊ូ របស់ក្រុមហ៊ុនមានមូលដ្ឋានស្ថិតនៅក្នុងស្រុកសន្ទុក ខេត្តកំពង់ធំ (មានផែនទីបង្ហាញទីតាំងជូនភ្ជាប់) ដែលមានទំហំ ៨.១០០ ហិកតា ត្រូវបានគ្រប់គ្រងដោយក្រុមហ៊ុននេះ ។

១០០. ក្នុងការគ្រប់គ្រងគំរោងវិនិយោគនេះ ក្រុមហ៊ុននឹងត្រូវធ្វើការបែងចែក ដើម្បីគ្រប់គ្រងប្រព័ន្ធការងារជា ០៤ការិយាល័យធំៗ គឺ:

១- ការិយាល័យ កិច្ចការរដ្ឋបាល (Administration Office) : ដែលរួមមានផ្នែកគ្រប់គ្រងរដ្ឋបាលបុគ្គលិក ផ្នែកគ្រប់គ្រងអចលនវត្ថុ និងផ្នែកការពារសន្តិសុខ ។

២- ការិយាល័យ បច្ចេកទេស និងពិនិត្យគុណភាព (Office of Technical Affair & Quality Control): ដែលរួមមានផ្នែកបច្ចេកទេស និងកិច្ចការពិនិត្យគុណភាព ។

៣- ការិយាល័យ ផែនការ និងគ្រប់គ្រងពលកម្ម (Office of Planning and Labor Management) : ដែលរួមមានផ្នែកធ្វើផែនការ និងចាត់តាំងគ្រប់គ្រង កំលាំងពលកម្ម ។

៤- ការិយាល័យ គណនេយ្យ-ហិរញ្ញវត្ថុ និង នាំចេញ (Office of Accounting-Finance and Exportation): ដែលរួមមានផ្នែកគ្រប់គ្រងការងារគណនេយ្យ-ហិរញ្ញវត្ថុ ការលក់ផលិតផល ផ្នែកម៉ាឃីតធីង-ទំនាក់ទំនង ទីផ្សារ និងផ្នែក គ្រប់គ្រងការ នាំចេញ-នាំចូល ។

១០១. រចនាសម្ព័ន្ធគ្រប់គ្រងនៃគំរោងវិនិយោគនេះ និងត្រូវបានរៀបចំដូចខាងក្រោម:

**រចនាសម្ព័ន្ធគ្រប់គ្រងការងារ**




Draft

## ៣-៦ ការវិភាគសេដ្ឋកិច្ចនៃគំរោងវិនិយោគ

### ៣-៦-១ ទុនវិនិយោគ និងការវិភាគលំហូរសាច់ប្រាក់

#### ៣-៦-១-១ ទុនសំរាប់វិនិយោគ

**១០២.** ដើម្បីដំណើរការងារវិនិយោគនេះក្រុមហ៊ុន **តាន បៀន កំពង់ធំ អភិវឌ្ឍន៍ កៅស៊ូ (TAN BIEN KAMPONG THOM APHIVATH CAOUTCHOUC CO., LTD.)** នឹងត្រូវការដើមទុនប្រមាណ ៤៩.៤២៤.០៦២.០០ ដុល្លាអាមេរិក សំរាប់ចំណាយលើការដាំដុះដំបូង-ការសាងសង់សំណង់ស៊ីវិល-ចំណាយលើការទិញមធ្យោបាយផលិតកម្ម និងចំណាយប្រតិបត្តិការអាជីវកម្ម ក្នុងដំណាក់កាល ១០ ឆ្នាំ ដំបូងនៃការអភិវឌ្ឍន។ ទុនវិនិយោគ ត្រូវបានបែងចែកតាមខ្ទង់ចំណាយដូចខាងក្រោម :

**ទុនវិនិយោគលំអិតតាមបណ្តាខ្ទង់ចំណាយ :**

| ប្រាក់ទុនវិនិយោគតាមមុខចំណាយ | | ទឹកប្រាក់ (គិតជាដុល្លាអាមេរិក) |
|---|---|---|
| *- ទុនសំរាប់ការងារដាំដុះដំបូង* | *Plantation Development* | 6,429,052.00 |
| *- ទុនសំរាប់សំណង់ស៊ីវិល* | *Civil Works* | 1,512,000.00 |
| *- ទុនសំរាប់ការសាងសង់រោងចក្រកែច្នៃ* | *Processing Factory* | 7,800,000.00 |
| *- ទុនសំរាប់គ្រឿងចក្រ* | *Heavy Equipment* | 1,020,000.00 |
| *- ទុនសំរាប់ចំណាយលើទព្វសំភារៈ ការិយាល័យ* | *Office Equipment* | 27,830.00 |
| *- ទុនសំរាប់ចំណាយប្រតិបត្តិការអាជីវកម្ម* | *Recurrent Costs* | 32,635,180.00 |
| *ទុនវិនិយោគសរុប* | | **49,424,062.00** |

Draft

**១០៣.** ដើមទុនដែលមានសមាមាត្រច្រើនជាងគេ គឺទុនសំរាប់ការចំណាយលើប្រតិបត្តិការអាជីវកម្មដាំដុះ ដែលមានប្រមាណ ៧១ ភាគរយ ( ៣២.៦៣៥.១៨០ ដុល្លាអាមេរិក) នៃដើមទុនសរុប ។ ដើមទុនសំរាប់ការងារដាំដុះដំបូងគ្រោងប្រមាណ ១៣ភាគរយ(៦.៤២៩.០៥២ ដុល្លាអាមេរិក) ទុនសំរាប់ការទិញគ្រឿងចក្រ ២ ភាគរយ (១.០២០.០០០ ដុល្លាអាមេរិក) ទុនសំរាប់ការដំឡើងរោងចក្រ ១៦ ភាគរយ(៧.៨០០.០០០ ដុល្លាអាមេរិក) ទុនសំរាប់ការសាងសង់សំណង់ស៊ីវិល ៣ ភាគរយ(១.៥១២.០០០ ដុល្លាអាមេរិក) និងទុនសំរាប់ការទិញទព្វសំភារៈការិយាល័យជិត ១ ភាគរយ(២៧.៨៣០ ដុល្លាអាមេរិក) ។ ក្រាហ្វិកខាងក្រោមនេះ គឺបង្ហាញច្បាស់អំពីការប្រើប្រាស់ទុនវិនិយោគតាមផ្នែកចំណាយនិមួយៗ ។




### ៣-៦-១-២ ការចំណាយសំរាប់រយៈពេល២០ឆ្នាំ

១០៤. ថវិកាដែលត្រូវវិនិយោគ លើគំរោងផលិតកម្មដំណាំកសិ-ឧស្សាហកម្ម : ដំណាំកៅស៊ូ និងការចំណាយកែច្នៃរយៈពេល១០ឆ្នាំដំបូង (២០០៨-២០១៧) គ្រោងនឹងចំណាយអស់ចំនួន ៥០.៩០០.៩៨៨ ដុល្លាអាមេរិក (ឧបសម្ព័ន្ធ៣-២: តារាង-៣ក) ។ ថវិកាដែលត្រូវចំណោយសំរាប់ប្រតិបត្តិការ ក្នុងគំរោងវិនិយោគនេះមានចំនួន ៣២.៦៣៥.១៨០ ដុល្លាអាមេរិក ដែលរួមមាន ចំណាយលើកំលាំងពលកម្ម ការដាំដុះ ការថែទាំដំណាំ ការប្រមូលផល ដឹកជញ្ជូន ចំណាយលើដំណើរការរោងចក្រកែច្នៃ និងចំណាយលើការដាំដុះជួសថ្មីឡើងវិញ។ ថវិកាសំរាប់ចំណាយលើការដាំដុះដំបូង ត្រូវបានគ្រោងប្រហែល ៦.៤២៩.០៥២ ដុល្លាអាមេរិក និងទឹកប្រាក់ប្រមាណ ១១.៨៣៦.៧៥៦ ដុល្លាអាមេរិក គ្រោងសំរាប់ចំណាយថេរ មិនមែនពន្ធ។



## ការចំណាយនៃការដាំដុះកៅស៊ូ រយៈពេល ២០ឆ្នាំដំបូង

| បណ្តាលឆ្នាំ | | ទឹកប្រាក់ចំណាយតាមឆ្នាំនីមួយៗ |
|---|---|---|
| ចំណាយឆ្នាំទី-១ | : | 2,647,691 |
| ចំណាយឆ្នាំទី-២ | : | 3,530,516 |
| ចំណាយឆ្នាំទី-៣ | : | 5,204,629 |
| ចំណាយឆ្នាំទី-៤ | : | 6,419,817 |
| ចំណាយឆ្នាំទី-៥ | : | 3,958,616 |
| ចំណាយឆ្នាំទី-៦ | : | 4,269,258 |
| ចំណាយឆ្នាំទី-៧ | : | 4,273,020 |
| ចំណាយឆ្នាំទី-៨ | : | 5,223,300 |
| ចំណាយឆ្នាំទី-៩ | : | 6,592,870 |
| ចំណាយឆ្នាំទី-១០ | : | 8,781,270 |
| ចំណាយឆ្នាំទី-១១ | : | 10,027,592 |
| ចំណាយឆ្នាំទី-១២ | : | 11,235,892 |
| ចំណាយឆ្នាំទី-១៣ | : | 12,361,817 |
| ចំណាយឆ្នាំទី-១៤ | : | 12,461,817 |
| ចំណាយឆ្នាំទី-១៥ | : | 12,561,817 |
| ចំណាយឆ្នាំទី-១៦ | : | 12,661,817 |
| ចំណាយឆ្នាំទី-១៧ | : | 12,661,817 |
| ចំណាយឆ្នាំទី-១៨ | : | 12,661,817 |
| ចំណាយឆ្នាំទី-១៩ | : | 12,661,817 |
| ចំណាយឆ្នាំទី-២០ | : | 12,661,817 |

ផ្សេង :

១- ការចំណាយលំអិត បង្ហាញជូនក្នុងឧបសម្ព័ន្ធ- ៣

២- ទឹកប្រាក់ចំណាយតាមបណ្តាលឆ្នាំ គឺគិតរួមចំណាយដាំដុះដំបូង ចំណាយអថេរ និងការដាំថ្មី និងចំណាយថេរ

Draft




## ៣-៦-១-៣ ការវិភាគលំហូរសាច់ប្រាក់

**១០៥.** យោងតាមការគណនាលំហូរសាច់ប្រាក់នៃក្រុមហ៊ុន (Cash Flow Projection) ដូចដែលបានរៀបរាប់លំអិត ក្នុងឧបសម្ព័ន្ធ៣-២ះតារាងឧបសម្ព័ន្ធ-២ក បង្ហាញថា ចាប់ពីឆ្នាំទី១ (២០០៨) សមតុល្យសាច់ប្រាក់អវិជ្ជមាន (-)បានកើតមានឡើងរហូតដល់ឆ្នាំទី៩ (២០១៦) គឺប្រមាណពី -២.៣៦៩.៥៨២ ដុល្លាអាមេរិក នៅ ឆ្នាំទី១ (គឺជាការអភិវឌ្ឍន៍លើការបង្កើតកសិដ្ឋាន និងការទិញគ្រឿងចក្រ និងជាពិសេសការចំណាយលើសំណង់ស៊ីវិល) ទឹកប្រាក់ចំនួន -២.៨៥៥.៣៧៨ ដុល្លាអាមេរិក នៅឆ្នាំទី២ និងកើនដល់ -៤.៣៩២.៤៩១ ដុល្លាអាមេរិក នៅឆ្នាំ ទី៣ -៥.៨៦០.២៧៩ នៅឆ្នាំទី៤ និតថយចុះត្រឹម -៤.០៦៥.១៧៨ ដុល្លាអាមេរិក នៅឆ្នាំទី៥។ នៅឆ្នាំទី៦-៩ លំហូរសាច់ប្រាក់ (-) ថយចុះជាបន្តបន្ទាប់ គឺពីជាង ៦.០៦៦.៨២០ ដុល្លាអាមេរិក នៅឆ្នាំទី៦ មកត្រឹម- ១.០៧៣.០៣៥ ដុល្លាអាមេរិក នៅឆ្នាំទី៩ ។

Draft

**១០៦.** ចាប់ពីឆ្នាំទី១០ ទៅ លំហូរសាច់ប្រាក់វិជ្ជមាន(+) បានចាប់ផ្តើមកើនពី ៤៩៣.៩៨៦ ដុល្លាអាមេរិក (នៅឆ្នាំទី១០) រហូតដល់ ៥.៦០៧.៥៣៨ ដុល្លាអាមេរិក នៅឆ្នាំទី១៣ ។ ការកើនឡើងនៃលំហូរសាច់ប្រាក់វិជ្ជមាន (+) គឺអាស្រ័យដោយប្រាក់ចំណូលដែលប្រមូលបានមកវិញពីការវិនិយោគ មានទំហំចាប់ពីឆ្នាំទី១១ ពីជាង ១១លាន ដុល្លាអាមេរិក រហូតដល់ជាង ១៧.៧ លាន ដុល្លាអាមេរិក នៅឆ្នាំទី១៣ ។



## ៣-៦-២ របាយការណ៍ចំណូល និងចំណេញ-ខាត

### ៣-៦-២-១ របាយការណ៍ចំណូល

#### ក-ផលិតផល និងចំណូលពីកៅស៊ូ :

**១០៧.** ផ្អែកតាមការផ្តល់ទិន្នន័យ ពីក្រុមអ្នកបច្ចេកទេសវៀតណាម បានអោយដឹងថា ផលិតផលដំណាំកៅស៊ូ ត្រូវបានប៉ាន់ស្មានថានឹងទទួលបានទិន្នផលដំបូង (ឆ្នាំជៀរជ័រទី-១) ប្រមាណ៨០០ គីឡូក្រាម ក្នុងមួយ ហិកតា និង ទិន្នផលអាចកើនរហូតចាប់ពី ឆ្នាំជៀរជ័រទី-២ ចន្លោះ ១.០០០ គីឡូក្រាម ក្នុងមួយហិកតា រហូតដល់ ២.០០០ នៅឆ្នាំជៀរជ័រទី-៤ និង កើតដល់ ២.៥០០ គីឡូក្រាម ក្នុងមួយហិកតា ពីឆ្នាំទី ៥-១៦។ ទិន្នផលកៅស៊ូ និងអាចធ្លាក់មកវិញត្រឹម ២.០០០ គីឡូក្រាម ក្នុងមួយហិកតា នៅឆ្នាំជៀរជ័រទី-១៧ និងថយមកត្រឹម ១.០០០-២.០០០ គីឡូក្រាម ក្នុងមួយហិកតា នៅចន្លោះឆ្នាំទី-១៧-១៩។ ចាប់ពីឆ្នាំទី-២០ទៅ ទិន្នផលនិងអាចធ្លាក់ដល់ ៨០០ គីឡូក្រាម ក្នុងមួយហិកតា ។

**តារាងទិន្នផលកៅស៊ូប៉ាន់ស្មាន** ឯកតាគិតជាគ.ក្រ/ហ.ត

| **ឆ្នាំចៀរ** | **ទិន្នផល** |
|---|---|
| ឆ្នាំទី-១ | ៨០០ |
| ឆ្នាំទី-២ | ១.០០០ |
| ឆ្នាំទី-៣ | ១.៥០០ |
| ឆ្នាំទី-៤ | ២.០០០ |
| ឆ្នាំទី-៥-១៦ | ២.៥០០ |
| ឆ្នាំទី-១៧ | ២.០០០ |
| ឆ្នាំទី-១៨ | ១.៥០០ |
| ឆ្នាំទី-១៩ | ១.០០០ |
| ឆ្នាំទី-២០-២៥ | ៨០០ |



**១០៨.** ការប៉ាន់ស្មានប្រាក់ចំណូលគិតជាដុល្លាអាមេរិក បានមកពីការលក់ជ័រកៅស៊ូស្ងួត នៅតាមឆ្នាំនីមួយៗ មានសភាពខុសៗគ្នា អាស្រ័យទៅតាមចំនួនដើមកៅស៊ូ ដែលដាំដុះលើផ្ទៃដីត្រូវបានពង្រីក ពីមួយឆ្នាំទៅមួយឆ្នាំ ច្រើនៗឡើងដែរ។ រយៈពេលដែលអាចចាប់ផ្តើមឱ្យផល គឺនៅឆ្នាំ ២០១៤ (រយៈពេល០៧ឆ្នាំ ចាប់ពីពេលដាំក្នុងចំការ)។ ក្រៅពីនេះតំលៃជ័រកៅស៊ូស្ងួត ជាកត្តាសំខាន់ក្នុងការប៉ាន់រកប្រាក់ចំណូលនៃគំរោងដាំដុះធ្វើអាជីវកម្ម ដំណាំកៅស៊ូនេះដែរ។ តាមនិន្នាការតំលៃទីផ្សារអន្តរជាតិ ដែលក្រុមហ៊ុនចំការកៅស៊ូទាំង៧ និងវិទ្យាស្ថានស្រាវជ្រាវដំណាំកៅស៊ូកម្ពុជា បាននាំចេញទៅលក់នៅក្រៅប្រទេសពីឆ្នាំ ១៩៩៨-២០០៤ ឃើញថាមានការប្រែប្រួលតែ ៦%ប៉ុណ្ណោះ។ នៅឆ្នាំ ២០០៤ តំលៃកៅស៊ូស្ងួតបានឡើងដល់ ១.១៧៥ ដុល្លាអាមេរិក/តោន ហើយនៅឆ្នាំ២០០៦នេះ តំលៃកៅស៊ូស្ងួតបានឡើងដល់ ១.២០០-១.៥០០ដុល្លាអា មេរិក/តោន ។

**១០៩.** តាមការគណនាផលិតផលកៅស៊ូ ឧបសម្ព័ន្ធ៣-២ (ឧបសម្ព័ន្ធ៤-ក) បានបង្ហាញថា នៅឆ្នាំទី៧ផលិតកម្មដំណាំកៅស៊ូ អាចផ្តល់បរិមាណផលសរុបបាន ៧០៤ តោន ហើយកើនរហូតពីមួយឆ្នាំទៅមួយឆ្នាំ តាមទំហំផ្ទៃដីអាជីវកម្ម ដល់ ៨.៥៤៥ តោន នៅឆ្នាំទី១០ (២០១៧) នៅឆ្នាំទី ១១-១៦ ផលិផលកៅស៊ូ ទទួលបានក្នុងចន្លោះ ១១.៤៦៥-១៨.៨៧៥ តោន។ ចន្លោះឆ្នាំទី ១៧-២២ ផលិតផលកៅស៊ូ ទទួលបានប្រហែល ១៨.៨៧៥ តោន ក្នុងមួយឆ្នាំ និងបានថយទិន្នផលបន្តិច គឺប្រហែល ១៨.៤៣៥ តោន ចាប់ពីឆ្នាំទី-២៣ មកត្រឹម ១០.២២៤ តោននៅឆ្នាំទី ២៦។ តម្លៃលក់ផលិតផល កៅស៊ូត្រូវប៉ាន់ស្មាន ជាមធ្យមប្រហែល ១.០៣០ ដុល្លាអាមេរិក ក្នុងមួយតោន សំរាប់គណនាចំណូលក្នុងផែនការមេនេះ ។

Draft

**១១០.** ចំណូលបានមកពីការលក់កៅស៊ូ នឹងអាចទទួលបាននៅឆ្នាំទី៧ ប្រហែល ៧២៥.១២០ ដុល្លាអាមេរិក និងកើនជាបន្តបន្ទាប់ពីមួយឆ្នាំទៅមួយឆ្នាំរហូតដល់ ៨.៨០១.៣៥០ ដុល្លាអាមេរិកនៅក្នុងឆ្នាំទី១០ (២០១៧)។ ចាប់ពីឆ្នាំទី១១-១៣ បរិមាណចំណូលបានកើនឡើង ក្នុងរង្វង់ពី ជាង ១១.៨ លានដុល្លាអាមេរិក ដល់ ជាង ១៧.៩ លានដុល្លាអាមេរិក និងបានកើនឡើងខ្លាំងនៅឆ្នាំទី ១៤-២២ (២០២១-២០២៩) គឺប្រមាណជាងទឹកប្រាក់ជាង ១៩.៤ លានដុល្លាអាមេរិក។ ចំណូលបានធ្លាក់ចុះមកវិញចាប់ពីឆ្នាំទី ២៣-២៦ (២០៣០-២០៣៣) ក្នុងបរិមាណទឹកប្រាក់ ជាង ១០-១៨ លានដុល្លាអាមេរិក។ (របាយការណ៍លំអិតមានបង្ហាញជូនក្នុងឧបសម្ព័ន្ធ៣-២: តារាងឧបសម្ព័ន្ធ ៤(ក.ខ))។

**ខ-ចំណូលសរុបពីការវិនិយោគដាំដំណាំកសិ-ឧស្សាហកម្ម**

**តារាងចំណូលពីការវិនិយោគ ពីឆ្នាំទី_២០១៤ ដល់ ឆ្នាំទី_២០៣៣**

| បណ្តាលឆ្នាំ | | ទឹកប្រាក់ចំណូល (USD) |
|---|---|---|
| ចំណូលឆ្នាំ ២០១៤ | : | 725,120 |
| ចំណូលឆ្នាំ ២០១៥ | : | 2,035,280 |

| | | |
|---|---|---|
| ចំណូលឆ្នាំ ២០១៦ | : | 4,789,500 |
| ចំណូលឆ្នាំ ២០១៧ | : | 8,801,350 |
| ចំណូលឆ្នាំ ២០១៨ | : | 11,808,950 |
| ចំណូលឆ្នាំ ២០១៩ | : | 15,244,000 |
| ចំណូលឆ្នាំ ២០២០ | : | 17,973,500 |
| ចំណូលឆ្នាំ ២០២១ | : | 19,441,250 |
| ចំណូលឆ្នាំ ២០២២ | : | 19,441.250 |
| ចំណូលឆ្នាំ ២០២៣ | : | 19,441,250 |
| ចំណូលឆ្នាំ ២០២៤ | : | 19,441,250 |
| ចំណូលឆ្នាំ ២០២៥ | : | 19,441,250 |
| ចំណូលឆ្នាំ ២០២៦ | : | 19,441,250 |
| ចំណូលឆ្នាំ ២០២៧ | : | 19,441,250 |
| ចំណូលឆ្នាំ ២០២៨ | : | 19,441,250 |
| ចំណូលឆ្នាំ ២០២៩ | : | 19,441,250 |
| ចំណូលឆ្នាំ ២០៣០ | : | 18,988,050 |
| ចំណូលឆ្នាំ ២០៣១ | : | 16,567,550 |
| ចំណូលឆ្នាំ ២០៣២ | : | 14,147.050 |
| ចំណូលឆ្នាំ ២០៣៣ | : | 10,53,720 |

Draft




### ៣-៦-២-២ របាយការណ៍ចំណេញ-ខាត

**១១១.** របាយការណ៍ចំណេញ-ខាត ពីឆ្នាំទី១-២០ ត្រូវបានបង្ហាញលំអិតក្នុងឧបសម្ព័ន្ធ៣-២ឧបសម្ព័ន្ធ-៣ក.ខ ភ្ជាប់ក្នុងផែនការមេនេះ ។ ទំហំផ្ទៃដីដាំដុះបានប្រែប្រួលក្នុងចន្លោះពី ៨៨០ ហិកតា ដល់ ២.៨៥០ ហិកតា ក្នុង

Draft

រយៈពេលបួនឆ្នាំដំបូង។ ផ្ទៃដីដាំដុះត្រូវបានប្រែប្រួលពីមួយឆ្នាំទៅមួយឆ្នាំ ដែលធ្វើថវិកាចំណាយក៏ប្រែប្រួលទៅតាម ទំហំនៃការដាំដុះ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានា។

**១១២.** យោងតាមរបាយការណ៍ចំណូលនិងចំណេញ-ខាត បានបង្ហាញថារបាយលារណ៏-ខាត (-) កើតមានឡើង ចាប់ពីឆ្នាំទី១ រហូតដល់ឆ្នាំទី១០។ ទឹកប្រាក់ចំនួន ២.៦៤៧.៦៩១ ដុល្លាអាមេរិក គឺជាការខាតបង់នៅឆ្នាំទី១ និង ៣.៥៣០.៥១៦ ដុល្លាអាមេរិក ជាទឹកប្រាក់ខាតជាលើកទី២។ របាយការណ៏ខាត នៅតែកើតមាននៅឆ្នាំទី ៣-៤ ចន្លោះ ពី ៥.២ លានដុល្លាអាមេរិក ដល់ ៦.៤ លានដុល្លាអាមេរិក អាស្រ័យដោយការកើនឡើង នៃចំណាយលើការដាំដុះ និង ការសាងសង់រោងចក្រកែច្នៃ។ នៅឆ្នាំទី៥ ក្រុមហ៊ុននៅមានការខាតត្រឹមតែ ៣.៩៥៨.៦៥៨ ដុល្លាអាមេរិក ហើយកើនបន្តិចវិញប្រមាណ ៤.២៦៩.២៥៨ ដុល្លាអាមេរិក នៅឆ្នាំទី៦។ ចាប់ពីឆ្នាំទី៧-១០ ទឹកប្រាក់ខាតបានថយចុះជាបន្តបន្ទាប់ពី ៣.៥៩៨.៦៥៨ ដុល្លាអាមេរិក នៅឆ្នាំទី៧ មកត្រឹម ៥៩៦.០១៥ ដុល្លាអាមេរិក នៅឆ្នាំទី១០ ។

**១១៣.** ការចំណាយដូចបានគណនានៅក្នុងរបាយការណ៏ចំណូល និងចំណេញ-ខាត ក្នុងឧបសម្ពន្ធ៣-២ : តារាងឧបសម្ពន្ធ ៣ក.ខ ត្រូវបានគណនាឃើញដូចខាងក្រោម :

| **របាយការណ៏ចំណេញ-ខាត ២០០៨-២០២៧** | | | **ទឹកប្រាក់ចំណូល (USD)** |
|---|---|---|---|
| របាយការណ៏ខាត ឆ្នាំទី-១ | (២០០៨) | : | -2,647,691 |
| របាយការណ៏ខាត ឆ្នាំទី-២ | (២០០៩) | : | -3,530,516 |
| របាយការណ៏ខាត ឆ្នាំទី-៣ | (២០១០) | : | -5,204,629 |
| របាយការណ៏ខាត ឆ្នាំទី-៤ | (២០១១) | : | -6,419,817 |
| របាយការណ៏ខាត ឆ្នាំទី-៥ | (២០១២) | : | -3,958,616 |
| របាយការណ៏ខាត ឆ្នាំទី-៦ | (២០១៣) | : | -4,269,258 |
| របាយការណ៏ខាត ឆ្នាំទី-៧ | (២០១៤) | : | -3,598,658 |
| របាយការណ៏ខាត ឆ្នាំទី-៨ | (២០១៥) | : | -3,330,490 |
| របាយការណ៏ចំណេញ ឆ្នាំទី-៩ | (២០១៦) | : | -2,138,635 |
| របាយការណ៏ចំណេញ ឆ្នាំទី-១០ | (២០១៧) | : | -596,015 |
| របាយការណ៏ចំណេញ ឆ្នាំទី-១១ | (២០១៨) | : | 954,732 |
| របាយការណ៏ចំណេញ ឆ្នាំទី-១២ | (២០១៩) | : | 2,941,028 |
| របាយការណ៏ចំណេញ ឆ្នាំទី-១៣ | (២០២០) | : | 4,353,538 |

Draft

| | | | |
|---|---|---|---|
| របាយការណ៍ចំណេញ ឆ្នាំទី-១៤ | (២០២១) | : | 5,618,546 |
| របាយការណ៍ចំណេញ ឆ្នាំទី-១៥ | (២០២២) | : | 5,518,546 |
| របាយការណ៍ចំណេញ ឆ្នាំទី-១៦ | (២០២៣) | : | 5,418,546 |
| របាយការណ៍ចំណេញ ឆ្នាំទី-១៧ | (២០២៤) | : | 5,418,546 |
| របាយការណ៍ចំណេញ ឆ្នាំទី-១៨ | (២០២៥) | : | 5,418,546 |
| របាយការណ៍ចំណេញ ឆ្នាំទី-១៩ | (២០២៦) | : | 5,418,546 |
| របាយការណ៍ចំណេញ ឆ្នាំទី-២០ | (២០២៧) | : | 5,418,546 |




Draft

**១១៤.** ប្រាក់ចំណេញសុទ្ធ (Net Income/Profit) ត្រូវបានប៉ាន់ស្មានថានឹងទទួលបានចាប់ពីឆ្នាំទី១១ ចំនួន ៩៥៤.៧៣២ ដុល្លាអាមេរិក។ នៅឆ្នាំទី១២ ប្រាក់ចំណេញសុទ្ធ ទទួលបានប្រហែល ២.៩៤១.០២៨ ដុល្លាអាមេរិកនៅឆ្នាំទី១៣ ទទួលបានប្រហែល ៤.៣៥៣.៥៣៨ ដុល្លាអាមេរិក ៥.៥១៨.៥៤៦ ដុល្លាអាមេរិក ជាទឹកប្រាក់ទទួលបាននៅឆ្នាំទី១៤។ ប្រាក់ចំណេញសុទ្ធទទួលបាន មានការថយចុះពីឆ្នាំទី១៦-២០ត្រឹម ៥.៤១៨.៥៤៦ ដុល្លាអាមេរិកឆ្នាំទី២០។

## ៣-៧ ប្រសិទ្ធិភាព និងភាពរឹងប៉ឹងនៃតំបន់ដីសម្បទាន

**១១៥.** យោងតាមរបាយការណ៍វិភាគសេដ្ឋកិច្ច អាជីវកម្មរបស់ក្រុមហ៊ុន បានបង្ហាញអំពីលំហូរសាច់ប្រាក់សុទ្ធ (Net Cash Flow) ដែលនឹងចាប់ផ្តើមប្រតិបត្តិការនៅ ឆ្នាំ ២០០៨ រហូតដល់ ឆ្នាំ ២០២៧ រយៈពេល២០ឆ្នាំ ក្នុងការអនុវត្ត នីគំរោងការដាំដុះ និងអាជីវកម្មដំណាំកៅស៊ូ គឺបង្ហាញថាៈ លំហូរសាច់ប្រាក់ មានការប្រែប្រួលពីមួយឆ្នាំទៅ មួយឆ្នាំអាស្រ័យទៅលើការបណ្តាក់ទុន និងចំណូលចំណាយលើកិច្ចប្រតិបត្តការហិរញ្ញវត្ថុ នៃឆ្នាំ

នីមួយៗ។ ទិន្នន័យសំរាប់ធ្វើការវិភាគប្រសិទ្ធិភាពសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ក្នុងផែនការមេនេះ គឺផ្អែកលើលំហូរសាច់ប្រាក់សុទ្ធ (មានលំអិតក្នុងឧបសម្ព័ន្ធ៣-២ : តារាងឧបសម្ព័ន្ធ-២ខ) ។

**១១៦.** ម្យ៉ាងវិញទៀត អនុលោមតាមទ្រឹស្តីវិនិយោគទុន អត្រាការប្រាក់ ឬអត្រាអប្បហារ ត្រូវបានយកមកគណនានៅក្នុងការរកប្រសិទ្ធិភាពហិរញ្ញវត្ថុ នៃគំរោងវិនិយោគ។ បច្ចុប្បន្នអត្រាការប្រាក់តាមបណ្តាធនាគារពាណិជ្ជកម្មនានា មានការខុសគ្នាបន្តិចបន្តួច ប៉ះរំបំរួលពី ៣% ទៅ ៦% ក្នុងមួយឆ្នាំ ក្នុងប្រភេទគណនី មានកាលកំណត់។

**១១៧.** ក្រុមហ៊ុនធ្វើការវិភាគភាពរឹងប៉ឹងនៃគំរោងវិនិយោគ តាមការគណនា**<u>តម្លៃបច្ចុប្បន្ន</u>** (PresentValue) នៃលំហូរសាច់ប្រាក់រយៈពេល២០ឆ្នាំដំបូង ដោយកំណត់យកអត្រា Marginal Cost Capital (Discount Rate ស្មើនឹង ៨% ការគណនា **<u>តម្លៃបច្ចុប្បន្នសុទ្ធ</u>** (Net Present Value or NPV) និងការគណនា Internal Rate of Return (IRR) ។ លទ្ធផលនៃការ គណនាបានបង្ហាញជូនដូច ខាងក្រោម :

- តម្លៃបច្ចុប្បន្ន (Present Value) = ២៩.២៥៩.៦៣៨ ដុល្លាអាមេរិក ក្រុមហ៊ុនត្រូវការដើមទុនអាជីវកម្ម សំរាប់ ១០ ឆ្នាំដំបូង គឺប្រមាណជាង ២៩.២ លានដុល្លាអាមេរិក ប្រសិនបើអត្រា Discount Rate=៨% ។
- តម្លៃបច្ចុប្បន្នសុទ្ធ (Net Present Value or NPV) = ៥.៤៧៤.៦១៣ ដុល្លាអាមេរិក: តម្លៃបច្ចុប្បន្នសុទ្ធនៃគំរោងវិនិយោគនេះ ជាចំនួនវិជ្ជមាន ដែលក្រុមហ៊ុនអាចសន្និដ្ឋានបានថា ការធ្វើអាជីវកម្មមានដំណើរការល្អ និងទទួលយកបាន។
- ការគណនា Intenal Rate of Return (IRR) = ១២% : តួលេខនេះគឺធ្វើឱ្យក្រុមហ៊ុនអាចមានក្តីសង្ឃឹមច្រើន ក្នុងការធ្វើអាជីវកម្មរបស់ខ្លួនព្រោះ Discounted Rate កំណត់ត្រឹម ៨%តូចជាង Intenal Rate of Return (IRR) អាចមានរហូតដល់ ១២ ភាគរយ។
- រយៈពេលប្រមូលទុនមកវិញ (Payback Period): ក្នុងរង្វង់រយៈពេល១៧ឆ្នាំ ក្រុមហ៊ុនអាចមានលទ្ធភាពទូទាត់សង និងប្រមូលបានមកវិញ នូវដើមទុនវិនិយោគនៃគំរោងអាជីវកម្មនេះ។
- សន្ទស្សន៍ផលចំណេញ (Profitability Index or Benefit/Cost Ratio) ក្នុងរយៈពេល ២០ ដំបូងនេះ ត្រូវបានគណនាឃើញប្រហែល ១.១៤។ គំរោងវិនិយោគនេះ អាចទទួលយកបានព្រោះសន្ទស្សន៍ផលចំណេញធំជាង០១ ឬអាចនិយាយបានថា ១ដុល្លាអាមេរិក ដែលបានវិនិយោគនឹងអាចបង្កើនតម្លៃបាន ១.១៤ ដុល្លាអាមេរិក។ (របាយការណ៍លំអិតមានក្នុង ឧបសម្ព័ន្ធ៣-២: តារាងឧបសម្ព័ន្ធ-២ខ : នៃផែនការមេនេះ)

Draft